ធនាគារជាតិ នៃ កម្ពុជា

ប្រាក់រៀល ស្ថិរភាព អភិវឌ្ឍន៍

# របាយការណ៍ប្រចាំឆ្នាំ



ឆ្នាំ ២០១៩

# មាតិកា

**អារម្ភកថា** ........ i
**អក្សរកាត់** ........ iv
**ខ្លឹមសារសង្ខេប** ........ vii
**ផ្នែកទី១ - របាយការណ៍ប្រចាំឆ្នាំ២០១៩**
**I- បរិស្ថានសេដ្ឋកិច្ចពិភពលោក** ........ ១
**II-ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា**
១- កំណើនសេដ្ឋកិច្ច ........ ៣
២- អតិផរណា ........ ៣
៣- អត្រាប្តូរប្រាក់ ........ ៥
៤- ស្ថានភាពជញ្ជីងទូទាត់ ........ ៦
៥- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ........ ៨
**III-ការគ្រប់គ្រងរូបិយវត្ថុ**
១- ស្ថានភាពរូបិយវត្ថុ ........ ៩
២- ឧបករណ៍គោលនយោបាយរូបិយវត្ថុ ........ ១១
**IV- ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា**
១- ស្ថានភាពទូទៅ ........ ១៤
២- វិស័យធនាគារ ........ ១៥
៣- វិស័យមីក្រូហិរញ្ញវត្ថុ ........ ១៦
៤- ភតិសន្យាហិរញ្ញវត្ថុ ........ ១៧
៥- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ១៨
៦- ការវិភាគស្ថិរភាពហិរញ្ញវត្ថុ ........ ១៨
៧- ការត្រួតពិនិត្យការិយាល័យឥណទាន ........ ២០
៨- ការងារបរិយាបន្នហិរញ្ញវត្ថុ និងការអប់រំផ្នែកហិរញ្ញវត្ថុ ........ ២០
**V- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល**
១- ប្រព័ន្ធទូទាត់សងប្រាក់ ........ ២៣
២- ប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់ ........ ២៤
៣- ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ ........ ២៥
**VI-ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា** (**ស.ហ.ក**)
១- ការរាយការណ៍ប្រតិបត្តិការរបស់បុគ្គលរាយការណ៍ ........ ២៨
២- ការងារពង្រឹងការអនុវត្តកាតព្វកិច្ចបុគ្គលរាយការណ៍ និងបង្កើនការយល់ដឹង ........ ២៨
៣- ការអនុវត្តសកម្មភាពការងារក្នុងយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣ ........ ២៨
៤- កិច្ចសហប្រតិបត្តិការ ........ ២៨

**VII- កិច្ចសហប្រតិបត្តិការអន្តរជាតិ**
១ -កិច្ចសហប្រតិបត្តិការពហុភាគី ........ ២៩
២ -កិច្ចសហប្រតិបត្តិការទ្វេភាគី ........ ៣០
**VIII- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា**
១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល ........ ៣១
២- ការអភិវឌ្ឍធនធានមនុស្ស ........ ៣២
៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ ........ ៣៣
៤- ការគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ........ ៣៤
**សន្និដ្ឋាន** ........ ៣៥
**ផ្នែកទី២ - ទិសដៅការងារ ឆ្នាំ២០២០**
១- ការអនុវត្តគោលនយោបាយរូបិយវត្ថុ ........ ៣៧
២- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ........ ៣៧
៣- ការអភិវឌ្ឍប្រព័ន្ធទូទាត់ ........ ៣៧
៤- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ........ ៣៨
៥- ការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ........ ៣៩
៦- ការងារប្រតិបត្តិការ ........ ៣៩
៧- ការបោះផ្សាយនិងឃ្លាំងបេឡា ........ ៣៩
៨- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងគ្រប់គ្រងហានិភ័យ ........ ៣៩
៩ - ការគ្រប់គ្រងសាខា ........ ៤០
១០- គណនេយ្យ ........ ៤០
១១-ការគ្រប់គ្រង និងបណ្តុះបណ្តាល ........ ៤០
១២-កិច្ចសហប្រតិបត្តិការអន្តរជាតិ ........ ៤១
១៣-ការស្រាវជ្រាវ និងវិភាគសេដ្ឋកិច្ច ........ ៤១
១៤- ស្ថិតិ ........ ៤១
**ផ្នែកទី៣ - ឧបសម្ព័ន្ធ**
ឧបសម្ព័ន្ធ ១ តារាង ១- ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវា ........ ៤៣
ឧបសម្ព័ន្ធ ២ តារាង ២- ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ) ........ ៤៤
ឧបសម្ព័ន្ធ ៣ តារាង ៣- ស្ថានភាពរូបិយវត្ថុ (ប៊ីលានរៀល) ........ ៤៥
ឧបសម្ព័ន្ធ ៤ តារាង ៤- ស្ថានភាពរូបិយវត្ថុ (បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ) ........ ៤៦
ឧបសម្ព័ន្ធ ៥ តារាង ៥- គណនីវិភាគធនាគារជាតិនៃកម្ពុជា ........ ៤៧
ឧបសម្ព័ន្ធ ៦ តារាង ៦- គណនីវិភាគធនាគារពាណិជ្ជ ........ ៤៨
ឧបសម្ព័ន្ធ ៧ តារាង ៧- ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច ........ ៤៩
ឧបសម្ព័ន្ធ ៨ តារាង ៨- សរុបប្រតិបត្តិការប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ ........ ៥០
ឧបសម្ព័ន្ធ ៩ តារាង ៩- ជញ្ជីងទូទាត់ប្រទេសកម្ពុជា ........ ៥១
ឧបសម្ព័ន្ធ ១០ តារាង ១០- បណ្តាញនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពីឆ្នាំ២០១២-២០១៩ ........ ៥២

# អារម្ភកថា

នៅឆ្នាំ២០១៩នេះ ការបន្តអូសបន្លាយនៃភាពតានតឹងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិកនិងចិនបានបន្ថយកំណើនសេដ្ឋកិច្ចពិភពលោកឱ្យមកនៅកម្រិតទាប ក្រោយពីបានងើបឡើងពីវិបត្តិហិរញ្ញវត្ថុពិភពលោក។ ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច ធនាគារកណ្តាលភាគច្រើនបានអនុវត្តគោលនយោបាយរូបិយវត្ថុវិត្ថារកម្ម តាមរយៈការបន្ទាបអត្រាការប្រាក់គោល ឬការចាក់បញ្ចូលទុនទៅក្នុងទីផ្សារ ក្នុងពេលដែលអតិផរណាបន្តស្ថិតក្នុងកម្រិតទាបនៅឡើយ។ កម្រិតទាបនៃអត្រាការប្រាក់គោលបានធ្វើឱ្យស្ថានភាពទីផ្សារហិរញ្ញវត្ថុអន្តរជាតិមានភាពធូរស្រាល និងជំរុញកំណើនលំហូរមូលធនទៅកាន់ប្រទេសកំពុងលូតលាស់ ក៏ប៉ុន្តែប្រសិនបើអត្រាការប្រាក់គោលបន្តមានកម្រិតទាបក្នុងរយៈពេលយូរ ហានិភ័យនិងភាពមិនប្រាកដប្រជានៅក្នុងទីផ្សារហិរញ្ញវត្ថុក៏អាចកើនឡើងផងដែរនាពេលខាងមុខ។

ដោយឡែក កម្ពុជាមិនបានទទួលរងឥទ្ធិពលដោយផ្ទាល់ពីការថមថយល្បឿនកំណើនសេដ្ឋកិច្ចពិភពលោកទេ ដោយវិស័យចម្បងៗនៃសេដ្ឋកិច្ចបន្តរីកចម្រើនរឹងមាំ ជាពិសេសវិស័យកម្មន្តសាលសំណង់ និងទេសចរណ៍។ ភាពល្អប្រសើរនៃស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងវឌ្ឍនភាពនៃការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល បានបន្តផ្តល់ថាមភាពដល់សេដ្ឋកិច្ចកម្ពុជា ដោយបន្តទាក់ទាញលំហូរវិនិយោគបរទេស ជំរុញការធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច និងពង្រឹងកំណើនតម្រូវការក្នុងស្រុក។ ទោះយ៉ាងណា ហានិភ័យចំពោះសេដ្ឋកិច្ចពិភពលោក អាចបង្កជាបញ្ហាប្រឈមដោយប្រយោលមកលើសេដ្ឋកិច្ចកម្ពុជា តាមរយៈផលប៉ះពាល់ដល់កំណើនក្នុងតំបន់អាស៊ី ជាពិសេសប្រទេសចិន ដោយសារកម្ពុជាមានភាពបើកទូលាយនិងសមាហរណកម្មខ្ពស់នៅក្នុងតំបន់។

ស្ថិតក្នុងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជាបានបន្តរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងភាពធន់នៃសេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែរឹងមាំ។ នាឆ្នាំ២០១៩កន្លងមក ថ្វីត្បិតតែការអនុវត្តគោល-នយោបាយរូបិយវត្ថុបន្តនៅមានកម្រិត ដោយសារបញ្ហាដុល្លារូបនីយកម្មខ្ពស់ ធនាគារជាតិនៃកម្ពុជាបន្តរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់ និងការគ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យមានកម្រិតសមស្របនៅក្នុងសេដ្ឋកិច្ច ដែលបានរួមចំណែកយ៉ាងសំខាន់ដល់ការរក្សាស្ថិរភាពថ្លៃ និងអំណោយផលដល់ការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ច។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានគរពូនទុនបម្រុងអន្តរជាតិឱ្យស្ថិតក្នុងកម្រិតខ្ពស់ ដើម្បីពង្រឹងការអនុវត្តគោលនយោបាយរូបិយវត្ថុ និងជំនឿទុកចិត្តមកលើសេដ្ឋកិច្ចកម្ពុជា។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ទាំងក្នុងវិស័យសាធារណៈនិងឯកជន និងប្រជាពលរដ្ឋគ្រប់រូប ចាំបាច់បន្តការចូលរួមបន្ថែមទៀតក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យបានទូលំទូលាយ។

នៅក្នុងវិស័យធនាគារ ការផ្តល់សេវាហិរញ្ញវត្ថុបានបន្តកើនឡើងយ៉ាងឆាប់រហ័ស ដែលគាំទ្រដល់កំណើនការវិនិយោគ ការប្រើប្រាស់ និងការសន្សំនៅក្នុងសេដ្ឋកិច្ច ដែលជាបច្ច័យរួមចំណែកបង្កើតការងារ លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រ។ ទន្ទឹមនេះ កំណើនការប្រើប្រាស់សេវាហិរញ្ញវត្ថុក៏ភ្ជាប់មកជាមួយនូវហានិភ័យ ដែលអាចបង្កឱ្យមានបំណុលលើសលប់ និងអស្ថិរភាពហិរញ្ញវត្ថុផងដែរ នៅពេលដែលចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅមានកម្រិត។ ឆ្លើយតបនឹងបញ្ហានេះ យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ត្រូវបានបង្កើតឡើង ដើម្បីរក្សាចីរភាពបរិយាបន្នហិរញ្ញវត្ថុ ហើយធនាគារជាតិនៃកម្ពុជាក៏បានលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុជាប្រចាំ ជាមួយនឹងការពង្រឹងកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា និងការផ្សព្វផ្សាយនានានៅទូទាំងប្រទេស។ ម្យ៉ាងទៀត ការត្រួតពិនិត្យនិងបទប្បញ្ញត្តិចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏ត្រូវបានពង្រឹងដោយផ្អែកលើហានិភ័យនិងទស្សនៈអនាគត ដើម្បីលើកកម្ពស់ការរក្សាស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា។

ជាមួយនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាក៏បានទាញយកអត្ថប្រយោជន៍ពីការអភិវឌ្ឍនេះផងដែរ តាមរយៈការអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងប្រតិបត្តិការដោយប្រុងប្រយ័ត្ន។ ទោះយ៉ាងណាបច្ចេកវិទ្យាហិរញ្ញវត្ថុមួយចំនួនក៏អាចបង្កជាហានិភ័យដល់វិស័យហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ចទាំងមូល ជាពិសេស ការទិញ-លក់ និងការចរាចរទ្រព្យសកម្ម Crypto ដែលទាមទារឱ្យមានការអភិវឌ្ឍក្របខ័ណ្ឌបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងលើបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ។ ទន្ទឹមនេះ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានធ្វើទំនើបកម្មទាំងការទូទាត់តម្លៃរាយនិងដុំតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានរួមចំណែកលើកកម្ពស់ប្រសិទ្ធភាពការទូទាត់ ជំរុញបរិយាបន្នហិរញ្ញវត្ថុ និងគាំទ្រដល់ការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច។

ដោយឡែក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានពង្រឹងប្រសិទ្ធភាពប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងបានដឹកនាំ សម្របសម្រួល និងសហការអនុវត្តការងារនានាដោយអនុវត្តតាមយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣។

ស្ថិតក្នុងបរិការណ៍ដែលសេដ្ឋកិច្ចពិភពលោកកាន់តែមានភាពប្រទាក់ក្រឡា និងស្មុគស្មាញ ការរួមចំណែកគាំទ្រក្នុងការពង្រឹងសមាហរណកម្មនិងសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ មានភាពចាំបាច់ ដើម្បីពង្រឹងបណ្តាញសុវត្ថិភាពហិរញ្ញវត្ថុតំបន់និងអន្តរជាតិ និងគាំទ្រចីរភាពកំណើន។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាធនាគារកណ្តាលអាជ្ញាធររូបិយវត្ថុ និងស្ថាប័នហិរញ្ញវត្ថុនានា ជាពិសេស ក្នុងក្របខ័ណ្ឌអាស៊ាន, អាស៊ាន+៣, ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ និងដៃគូយុទ្ធសាស្ត្រនានា។

នៅឆ្នាំ២០១៩នេះ ធនាគារជាតិនៃកម្ពុជាបានប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤០នៃការបង្កើតឡើងវិញនៃធនាគារជាតិនៃកម្ពុជា និងបានសម្ពោធជាផ្លូវការសារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុព្រះស្រីល្បសានវ័ន្ត។ ប្រព័ន្ធធនាគារបានឆ្លងកាត់នូវដំណាក់កាលដ៏លំបាកជាច្រើនរហូតដល់មានការអភិវឌ្ឍដូចបច្ចុប្បន្ន ជាពិសេសបន្ទាប់ពីកម្ពុជាទទួលបានសុខសន្តិភាព និងស្ថិរភាពនយោបាយពេញលេញចាប់ពីចុងឆ្នាំ ១៩៩៨មក ក្រោមការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងការកោតសរសើរនិងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អតីតទេសាភិបាល ក្រុមប្រឹក្សាភិបាល ថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ ដែលបានរួមចំណែកក្នុងការកសាងប្រព័ន្ធធនាគារឱ្យមានការអភិវឌ្ឍប្រកបដោយទំនុកចិត្ត។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អនារយៈពេលកន្លងមក។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ និងភាគីពាក់ព័ន្ធនានា នឹងបន្តគាំទ្រនិងរួមចំណែកសម្រេចបាននូវសមិទ្ធផលថ្មីៗបន្ថែមទៀត ដែលជាគុណប្រយោជន៍សម្រាប់ជាតិមាតុភូមិ និងប្រជាជនកម្ពុជាទាំងអស់។

**ទេសាភិបាល**

**ជា.ចាន់តូ**

# អក្សរកាត់

| | | |
|---|---|---|
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប | Gross Domestic Product (GDP) |
| ស.ហ.ក | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា | Cambodia Financial Intelligence Unit |
| ABIF | ក្របខ័ណ្ឌសមាហរណកម្មវិស័យធនាគារអាស៊ាន | ASEAN Banking Integration Framework |
| ACCA | សមាគមគណនេយ្យករជំនាញ | Association of Certified Chartered Accountants |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank |
| ADBI | វិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី | Asian Development Bank Institute |
| AFI | សហព័ន្ធដើម្បីបរិយាបន្នហិរញ្ញវត្ថុ | Alliance for Financial Inclusion |
| APG | ក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្ដីពីការសម្អាតប្រាក់ | Asia/Pacific Group on Money Laundering |
| APRACA | សមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក | Asia-Pacific Rural and Agricultural Credit Association |
| ATM | ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ | Automated Teller Machine |
| AUSTRAC | អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអូស្ត្រាលី | Australian Transaction Reports and Analysis Centre |
| BCLMV | ព្រុយណេ កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម | Brunei, Cambodia, Myanmar and Vietnam |
| BIS | ធនាគារសម្រាប់ការទូទាត់អន្តរជាតិ | Bank for International Settlements |
| CMIM | ពហុភាវូបនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ | Chiang Mai Initiative Multilateralization |
| CFA | អ្នកវិភាគហិរញ្ញវត្ថុជំនាញ | Chartered Financial Analyst |
| CIA | សវនកម្មផ្ទៃក្នុងជំនាញ | Certified Internal Audit |
| CPA | គណនេយ្យករសាធារណៈជំនាញ | Certified Public Accountant |
| EGMONT | ក្រុមអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ | Egmont Group of Financial Intelligence Units |
| EMV | អឺរ៉ូផេ, ម៉ាស្ទឺកាត, និងវីសា | Europay, MasterCard and Visa |
| ENEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ | Export-weighted Nominal Effective Exchange Rate |
| EREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ | Export-weighted Real Effective Exchange Rate |

| | | |
|---|---|---|
| ESG | បរិស្ថាន សង្គម និងអភិបាលកិច្ច | Environmental, Social and Governance |
| FICG | ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ | Financial Intelligence Consultative Group |
| FinTech | បច្ចេកវិទ្យាហិរញ្ញវត្ថុ | Financial Technology |
| FMIS | ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ | Financial Management Information System |
| FPP | កម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ | Financial Programing and Policies |
| FSB-RGC for Asia | ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុប្រចាំតំបន់អាស៊ី | Financial Stability Board-Regional Consultative Group for Asia |
| FSI Connect | កម្មវិធីសិក្សារបស់វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ | Financial Stability Institute Connect |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ | International Monetary Fund |
| INEER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល | Import-weighted Nominal Effective Exchange Rate |
| IREER | អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល | Import-weighted Real Effective Exchange Rate |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន | Japan International Cooperation Agency |
| KOICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ | Korea International Cooperation Agency |
| LIBOR | អត្រាការប្រាក់ LIBOR | London Interbank Offered Rate |
| LPCO | ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា | Liquidity-Providing Collateralized Operation |
| NCD | មូលបត្រអាចជួញដូរបាន | Negotiable Certificate of Deposit |
| OBS | ប្រព័ន្ធធនាគារអនឡាញ | Online Banking System |
| OECD | អង្គការដើម្បីអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច | Organization for Economic Co-operation and Development |
| OPEC | អង្គការនៃប្រទេសនាំចេញប្រេង | Organization of the Petroleum Exporting Countries |
| ROA | អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | Return on Assets |
| SAA | ការបែងចែកទ្រព្យសកម្មជាយុទ្ធសាស្ត្រ | Strategic Asset Allocation |

| | | |
|---|---|---|
| UNOCD | ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀននិងបទឧក្រិដ្ឋ | United Nations Office on Drugs and Crime |
| WC-ABIF | គណៈកម្មាធិការក្របខ័ណ្ឌសមាហរណកម្មវិស័យធនាគារអាស៊ាន | Working Committee on ASEAN Banking Integration Framework |
| WC-CAL | គណៈកម្មាធិការសេរីភាវូបនីយកម្មគណនីមូលធន | Working Committee on Capital Account Liberalization |
| WC-CMD | គណៈកម្មាធិការអភិវឌ្ឍទីផ្សារទុន | Working Committee on Capital Market Development |
| WC-FINC | គណៈកម្មាធិការបរិយាបន្នហិរញ្ញវត្ថុ | Working Committee on Financial Inclusion |
| WC-FSL | គណៈកម្មាធិការសេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ | Working Committee on Financial Services Liberalization |
| WC-PSS | គណៈកម្មាធិការប្រព័ន្ធទូទាត់សងប្រាក់ | Working Committee on Payment and Settlement System |
| WC-SCCB | គណៈកម្មាធិការដឹកនាំការកសាងសមត្ថភាព | Working Committee on Steering Committee on Capacity Building |

# ខ្លឹមសារសង្ខេប

កំណើនសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០១៩នេះ ត្រូវបានប៉ាន់ស្មានថានឹងថយចុះមកត្រឹម ៣% (៣,៦% នៅឆ្នាំ២០១៨) ដែលជាកម្រិតទាបបំផុតក្រោយពីវិបត្តិហិរញ្ញវត្ថុពិភពលោកនៅឆ្នាំ២០០៨។ ទន្ទឹមនេះ កំណើនសេដ្ឋកិច្ចអាស៊ានក៏នឹងអាចថយចុះមកត្រឹម ៤,៨% (៥,២% នៅឆ្នាំ២០១៨)។

ដោយឡែកនៅកម្ពុជា កំណើនសេដ្ឋកិច្ចរំពឹងថាសម្រេចបានក្នុងអត្រា ៧,១% ធៀបនឹង ៧,៥% នៅឆ្នាំ២០១៨ ដែលគាំទ្រជាចម្បងដោយការនាំចេញ វិស័យសំណង់ និងទេសចរណ៍។ ជញ្ជីងទូទាត់ត្រូវបានប៉ាន់ស្មានថានឹងមានអតិរេក ៩,៧% នៃផ.ស.ស. និងបានបន្តរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិដុលដល់ ១៨ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាលើការនាំចូលទំនិញ និងសេវាសម្រាប់គ្រាបន្ទាប់បានប្រមាណ ៧ខែ ខ្ពស់ជាងកម្រិតអប្បបរមាចំនួន ៣ខែ ដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។

អត្រាអតិផរណាត្រូវបានប៉ាន់ស្មានថានឹងស្ថិតក្នុងកម្រិតទាប ១,៩% (ធៀបនឹង ២,៥% នៅឆ្នាំ២០១៨) ដោយសារកំណើនថ្លៃទាបនៃក្រុមម្ហូបអាហារ និងក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ។ កម្រិតទាបនៃអតិផរណានេះ ត្រូវបានចូលរួមចំណែកគាំទ្រដោយការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់ក្នុងរង្វង់ ៤.០៥៥ រៀលក្នុងមួយដុល្លារអាមេរិក។ ខណៈដែលការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់នៅតែជាគោលនយោបាយចម្បង ឧបករណ៍គោលនយោបាយរូបិយវត្ថុផ្សេងទៀត ក៏ត្រូវបានអភិវឌ្ឍ ជាពិសេស មូលបត្រអាចជួញដូរបាន (NCD) និងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)។ ការស្រូបយកសន្ទនីយភាពលើសតាមរយៈ NCD បានថយចុះ ១២% ខណៈដែលការផ្គត់ផ្គង់សន្ទនីយភាពជាប្រាក់រៀលតាមរយៈប្រតិបត្តិការ LPCO បានកើនឡើងគួរឱ្យកត់សម្គាល់។ ទំហំទឹកប្រាក់ LPCO ដែលស្នើសុំដេញថ្លៃកើនឡើង ៦,៣ដង ហើយទំហំទឹកប្រាក់ដែលដេញថ្លៃបានជោគជ័យ កើនឡើង ៣,៩ ដង ធៀបនឹងឆ្នាំ២០១៨។ គួររំលេចថា តម្រូវការប្រាក់រៀលបានកើនឡើងជាលំដាប់ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនប្រាក់រៀលក្នុងចរាចរណ៍ (៣៣%) និងកំណើនប្រាក់បញ្ញើជារៀល (៣៧%)។ កំណើននេះបានបន្ទាបកម្រិតដុល្លារូបនីយកម្មបន្តិច (វាស់ដោយអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅ) មកត្រឹម ៨២,៩% ធៀបនឹង ៨៤,៨% នៅឆ្នាំមុន។

វិស័យធនាគារបន្តរីកចម្រើនយ៉ាងឆាប់រហ័ស ដែលបានរួមចំណែកយ៉ាងសកម្មគាំទ្រការរីកចម្រើននៃសេដ្ឋកិច្ច។ ទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនឡើង ២៤,៥% (ដល់ ១៩០% នៃផ.ស.ស.) ហើយឥណទានបានកើន ២៦% (ដល់ ១២០% នៃផ.ស.ស)។ បណ្តាញប្រតិបត្តិការនិងពិពិធកម្មសេវាហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ត្រូវបានបន្តពង្រឹង និងបានជួយជំរុញបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា ដោយបច្ចុប្បន្ន ចំនួនគណនីប្រាក់បញ្ញើបានកើនឡើងដល់ប្រមាណ ៧,៥ លានគណនី និងគណនីឥណទានកើនដល់ ៣,១ លានគណនី។ ជាមួយគ្នានេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសុខភាពល្អ ដោយគុណភាពឥណទានបន្តមានភាពល្អប្រសើរ ហើយអនុបាតឥណទានមិនដំណើរការស្ថិតក្នុងកម្រិតទាប ២,២% សម្រាប់គ្រឹះស្ថានធនាគារ និង ១,១% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ អនុបាតសាធនភាពនិងអនុបាតក្របខ័ណ្ឌសន្ទនីយភាពសម្រាប់គ្រឹះស្ថានធនាគារមានកម្រិតខ្ពស់ ២៤,៥% និង ១៧០,៨% និងសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

ទទួលប្រាក់បញ្ញើមានកម្រិត ១៩,២% និង ១៨៣,៥% រៀងគ្នា ស្របពេលដែលអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មសម្រាប់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុមានកម្រិតប្រមាណ ២% និង ២,៨% រៀងគ្នា។

ស្របតាមការរីកចម្រើននៃសកម្មភាពសេដ្ឋកិច្ចនិងបច្ចេកវិទ្យាហិរញ្ញវត្ថុ ប្រព័ន្ធទូទាត់ក៏ត្រូវបាននិងកំពុងបន្តអភិវឌ្ឍឱ្យកាន់តែទំនើបនិងមានភាពងាយស្រួល។ បច្ចុប្បន្ន ប្រជាជនប្រមាណ ៥លាននាក់កំពុងប្រើប្រាស់សេវាទូទាត់សងប្រាក់តាមអេឡិចត្រូនិក ដែលមាន ៧៧លានប្រតិបត្តិការ និងមានទំហំទឹកប្រាក់ប្រមាណ ៩៤ ទ្រីលានរៀល។ ធនាគារជាតិនៃកម្ពុជាកំពុងអភិវឌ្ឍស្តង់ដារ QR Code ដើម្បីសម្រួលដល់ការទូទាត់ឆ្លងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិការទូទាត់ឆ្លងដែន។ លើសពីនេះ ប្រព័ន្ធបាគងត្រូវបានដាក់ឱ្យដំណើរការសាកល្បង ហើយប្រព័ន្ធរីថៃលផេ (Retail Pay) ក៏ត្រូវបានដាក់ឱ្យដំណើរការជាបឋម បន្ថែមពីលើប្រព័ន្ធសេវាទូទាត់រហ័ស និងប្រព័ន្ធខេមបូឌានស៊ែស្វីច ដែលកំពុងទទួលបានការចូលរួមពីគ្រឹះស្ថានសមាជិកថ្មីៗបន្ថែមទៀត។

ឆ្លើយតបនឹងការកើនឡើងនៃប្រតិបត្តិការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងនៅក្នុងប្រទេសនិងអន្តរជាតិ ការគ្រប់គ្រងចរាចរណ៍សាច់ប្រាក់ត្រូវបានធ្វើឡើង ប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព ព្រមទាំងបានរួមចំណែកនៅក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។ ធនាគារជាតិនៃកម្ពុជាក៏បានបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាលំដាប់និងផ្អែកតាមស្ថានភាពទីផ្សារ។

ដោយឡែក អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ក៏បានដឹកនាំ សម្របសម្រួល និងសហការអនុវត្តការងារនានា ដើម្បីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា ហើយយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣ ក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីខែមីនាកន្លងទៅនេះ។

ក្នុងស្ថានភាពដែលវិស័យធនាគារមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងមានភាពប្រទាក់ក្រឡាជាមួយតំបន់និងពិភពលោក ការពង្រឹងសមត្ថភាពមន្ត្រីនៃធនាគារជាតិនៃកម្ពុជាត្រូវបានធ្វើឡើងជាប្រចាំ ទាំងចំណេះដឹងផ្នែកទន់និងជំនាញឯកទេសកម្ម តាមរយៈការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងការសិក្សាតាមប្រព័ន្ធអនឡាញ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាមានមន្ត្រីបុគ្គលិកសរុបចំនួន ១.៦៦៧រូប ក្នុងនោះ មន្ត្រីបុគ្គលិកដែលមានកម្រិតសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅមានរហូតដល់ ៦០% នៃចំនួនមន្ត្រីបុគ្គលិកសរុប។

ធនាគារជាតិនៃកម្ពុជាក៏បានពង្រឹងសមត្ថភាពប្រតិបត្តិការនៅតាមសាខារាជធានី-ខេត្តជាប្រចាំ ដើម្បីគាំទ្រដល់ការរីកចម្រើននៃវិស័យធនាគារនិងសេវាសាធារណៈ ស្របពេលដែលដំណើរការអភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារជាតិនៃកម្ពុជា ក៏ត្រូវបានលើកកម្ពស់តាមរយៈការធ្វើសវនកម្មនិងអធិការកិច្ចជាប្រចាំផងដែរ។

នាឆ្នាំ២០២០ខាងមុខ កំណើនសេដ្ឋកិច្ចពិភពលោករំពឹងថានឹងងើបឡើងវិញបន្តិចក្នុងកម្រិតប្រមាណ ៣,៤% ដោយសារភាពប្រសើរឡើងនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសកំពុងលូតលាស់ គួបផ្សំនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុវិក្ខារកម្ម។ ទន្ទឹមនេះ សេដ្ឋកិច្ចពិភពលោកក៏អាចប្រឈមនឹងហានិភ័យចម្បងៗមួយចំនួន រួមមាន ភាពតានតឹងនៃពាណិជ្ជកម្មអន្តរជាតិនិងការអនុវត្ត

គោលនយោបាយគាំពារនិយម, ភាពងាយប្រែប្រួលនៃលំហូរមូលធន, កត្តាភូមិសាស្ត្រនយោបាយ និងបម្រែបម្រួលអាកាសធាតុ។

ចំពោះកម្ពុជា កំណើនសេដ្ឋកិច្ចរំពឹងថាអាចសម្រេចបានក្នុងរង្វង់ ៧% នៅឆ្នាំ២០២០ ជាមួយនឹងកម្រិតទាបនៃអតិផរណាដែលរំពឹងថានឹងមានកម្រិត ២,៣%។ ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាក៏អាចប្រឈមនឹងហានិភ័យមួយចំនួន ដូចជា i/-ការអាចធ្លាក់ចុះជាងការរំពឹងទុកនៃកំណើនសេដ្ឋកិច្ចចិន ដោយសារភាពតានតឹងនៃពាណិជ្ជកម្មនិងបច្ចេកវិទ្យាជាមួយសហរដ្ឋអាមេរិក ii/-និន្នាការនៃការអនុវត្តគោលនយោបាយគាំពារនិយម និង iii/-កម្រិតខ្ពស់នៃកំណើនឥណទានទៅកាន់វិស័យសំណង់និងអចលនទ្រព្យ។

ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាពនិងបរិយាបន្ន ធនាគារជាតិនៃកម្ពុជា នឹងបន្តលើកកម្ពស់ប្រសិទ្ធភាពគោលនយោបាយរូបិយវត្ថុសំដៅរក្សាស្ថិរភាពថ្លៃ តាមរយៈការរក្សាស្ថិរភាពអត្រាប្តូរប្រាក់, បន្តគរពូនទុនបម្រុងអន្តរជាតិឱ្យមានកម្រិតខ្ពស់, លើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល និងអភិវឌ្ឍទីផ្សារអន្តរធនាគារ ជាដើម។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជា នឹងបន្តពង្រឹងស្ថិរភាពហិរញ្ញវត្ថុ, បរិយាបន្នហិរញ្ញវត្ថុ និងសមាហរណកម្មហិរញ្ញវត្ថុ ស្របតាមនិន្នាការតំបន់និងស្ថានភាពអភិវឌ្ឍរបស់កម្ពុជា ជាពិសេស ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដោយផ្អែកលើហានិភ័យនិងទស្សនអនាគត, ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា និងពង្រឹងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុក្នុងកម្រិតតំបន់និងពិភពលោក។

# ផ្នែកទី១- របាយការណ៍ប្រចាំឆ្នាំ២០១៩

## I- បរិស្ថានសេដ្ឋកិច្ចពិភពលោក

នៅឆ្នាំ២០១៩ កំណើនសេដ្ឋកិច្ចពិភពលោកបានបន្តថមថយល្បឿនបន្ថែមទៀត ដោយសារការថយចុះនៃសកម្មភាពពាណិជ្ជកម្មអន្តរជាតិនិងការវិនិយោគ ក្នុងពេលដែលភាពតានតឹងផ្នែកពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិកនិងចិននៅតែបន្តកើតមាន។ យោងតាមការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងឆ្នាំនេះ សេដ្ឋកិច្ចពិភពលោកមានកំណើនត្រឹមតែ ៣% ដែលជាកំណើនមួយទាបជាងគេចាប់តាំងពីការងើបឡើងវិញនៃសេដ្ឋកិច្ចក្រោយវិបត្តិហិរញ្ញវត្ថុពិភពលោកនៅឆ្នាំ២០០៨មក។ ទោះយ៉ាងណា កំណើនសេដ្ឋកិច្ចនេះត្រូវបានប៉ាន់ស្មានថានឹងងើបឡើងវិញនៅឆ្នាំ២០២០ ដល់ប្រមាណ ៣,៤%។

កំណើនសេដ្ឋកិច្ចសហរដ្ឋអាមេរិកថមថយល្បឿនបន្តិចពីប្រមាណ ២,៩% ក្នុងឆ្នាំ២០១៨ មកត្រឹម ២,៤% ក្នុងឆ្នាំនេះ ដោយសារការចុះខ្សោយឥទ្ធិពលនៃការអនុវត្តគោលនយោបាយសារពើពន្ធវិត្ថារកម្ម គួបផ្សំជាមួយភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្ម។ ទន្ទឹមនេះ កំណើនសេដ្ឋកិច្ចតំបន់អឺរ៉ូក៏បានថយល្បឿនមកត្រឹម ១,២% ធៀបនឹងឆ្នាំកន្លងទៅ (១,៩%) ដោយសារភាពទន់ខ្សោយនៃតម្រូវការខាងក្រៅ និងជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់និងវិនិយោគិននៅក្នុងប្រទេសធំៗក្នុងតំបន់ជាពិសេសអាល្លឺម៉ង់ អ៊ីតាលី និងបារាំង គួបផ្សំនឹងភាពមិនច្បាស់លាស់នៃការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប។ ប្រទេសចិនកំពុងទទួលរងឥទ្ធិពលពីភាពតានតឹងនៃពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក គួបផ្សំនឹងភាពទន់ខ្សោយនៃតម្រូវការពីខាងក្រៅ ដែលបានធ្វើឱ្យកំណើនសេដ្ឋកិច្ចប្រទេសនេះថយពី ៦,៦% ក្នុងឆ្នាំ២០១៨ មកត្រឹម ៦,១%។ ចំពោះតំបន់អាស៊ាន-៥ កំណើនសេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានថានឹងបន្ថយល្បឿនបន្តិចពី ៥,២% នៅឆ្នាំ២០១៨ មកត្រឹម ៤,៨% ជាចម្បងបណ្ដាលមកពីឥទ្ធិពលនៃភាពតានតឹងពាណិជ្ជកម្មរវាងចិននិងសហរដ្ឋអាមេរិក។

**ក្រាហ្វ ១៖ កំណើនសេដ្ឋកិច្ចនិងទំហំពាណិជ្ជកម្មពិភពលោក**
(ភាគរយ, ឆ្នាំ២០១៨ - ២០២០ព្យាករណ៍)




**ក្រាហ្វ ២៖ កំណើនសេដ្ឋកិច្ចប្រទេសធំៗ**
(ឆ្នាំ២០១៨ - ២០២០ព្យាករណ៍)




ប្រភព៖ មូលនិធិរូបិយវត្ថុអន្តរជាតិ

ហានិភ័យចម្បងមួយចំនួនដែលអាចប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចពិភពលោក រួមមាន៖ i/-ភាពតានតឹងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិកនិងចិន ii/-ភាពមិនប្រាកដប្រជានៃការចាកចេញរបស់អង់គ្លេសពីសហភាពអឺរ៉ុប iii/-ភាពងាយប្រែប្រួលនៃលំហូរមូលធនចេញពីប្រទេសកំពុងលូតលាស់និងប្រទេសកំពុងអភិវឌ្ឍន៍ iv/-ការកើនឡើងភាពងាយរងគ្រោះក្នុងវិស័យហិរញ្ញវត្ថុដែលបណ្ដាលមកពីគោលនយោបាយរូបិយវត្ថុវិត្ថារកម្ម v/-ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងvi/-បញ្ហានៃការប្រែប្រួលអាកាសធាតុ។

## ប្រអប់ ១ ៖ ការអនុវត្តគោលនយោបាយរូបិយវត្ថុក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច

បន្ទាប់ពីបានរឹតត្បិតជំហរគោលនយោបាយរូបិយវត្ថុបន្តិចនៅឆ្នាំមុន ធនាគារកណ្តាលភាគច្រើន ទាំងនៅប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងលូតលាស់ បានបន្ធូរបន្ថយមកវិញនៅឆ្នាំនេះ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ក្នុងពេលដែលអតិផរណាមានកម្រិតទាប។ ធនាគារកណ្តាលសហរដ្ឋ-អាមេរិកបានទម្លាក់អត្រាការប្រាក់គោលចំនួន៣លើក មកត្រឹម ១,៧៥% ក្រោយពីបានដំឡើងចំនួន ៤លើក ក្នុងឆ្នាំ២០១៨កន្លងទៅ។ ស្របពេលជាមួយគ្នានេះ ធនាគារកណ្តាលអឺរ៉ុបបានបញ្ជាក់ថា នឹងរក្សាអត្រាការប្រាក់គោលត្រឹម 0% យ៉ាងហោចណាស់រហូតដល់ឆមាសទី២ ឆ្នាំ២០២០ ហើយត្រៀមអនុវត្តប្រតិបត្តិការផ្តល់ហិរញ្ញប្បទានរយៈពេលវែង ចាប់ពីខែកញ្ញាឆ្នាំនេះ រហូតដល់ខែមីនា ឆ្នាំ២០២១ ដើម្បីជំរុញកំណើនឥណទាននៅក្នុងសេដ្ឋកិច្ច។ ចំណែកឯ ធនាគារកណ្តាលជប៉ុនក៏បន្តអនុវត្តគោលនយោបាយរូបិយវត្ថុរិត្បារកម្មដូចគ្រាមុនដែរ តាមរយៈការរក្សាអត្រាការប្រាក់គោលក្នុងកម្រិតអវិជ្ជមាន (-0,១%) និងការចាក់បញ្ចូលសន្ទនីយភាពទៅក្នុងទីផ្សារតាមរយៈការទិញសញ្ញាប័ណ្ណ ដើម្បីជំរុញអតិផរណាឱ្យកើនឡើងដល់កម្រិតអត្រាគោលដៅ។

ស្របពេលជាមួយគ្នានេះ ធនាគារកណ្តាលនៃប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ក្នុងតំបន់មួយចំនួន ក៏បានបន្ធូរបន្ថយជំហរគោលនយោបាយរូបិយវត្ថុផងដែរ ដូចជាធនាគារកណ្តាលចិនបានបន្ទាបអត្រាប្រាក់បម្រុងកាតព្វកិច្ចបន្ថែមទៀតនៅដើមឆ្នាំនេះ ក្រោយពីបានទម្លាក់ ៤លើក នៅឆ្នាំមុន ក្នុងគោលដៅជួយជំរុញសកម្មភាពសេដ្ឋកិច្ចដែលកំពុងថមថយ។ ទន្ទឹមនេះ ធនាគារកណ្តាល ថៃ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី វៀតណាម និងហ្វីលីពីន សុទ្ធតែបានទម្លាក់អត្រាការប្រាក់គោលដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ចរបស់ពួកគេ ខណៈដែលអត្រាអតិផរណានៅក្នុងកម្រិតទាបនៅឡើយ។

**អត្រាការប្រាក់គោលនៃប្រទេសអភិវឌ្ឍន៍**

(ខែមករា ឆ្នាំ២០១៦ - ខែតុលា ឆ្នាំ២០១៩)




**អត្រាការប្រាក់គោលក្នុងតំបន់**

(ខែមករា ឆ្នាំ២០១៥ - ខែតុលា ឆ្នាំ២០១៩)




ប្រភព៖ Trading Economics

## II- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា

### ១- កំណើនសេដ្ឋកិច្ច

នៅឆ្នាំ២០១៩នេះ សកម្មភាពសេដ្ឋកិច្ចកម្ពុជានៅបន្តមានវឌ្ឍនភាពល្អប្រសើរ ជាមួយនឹងកំណើន ៧,១% ដែលជំរុញដោយវិស័យកម្មន្តសាល សំណង់ និងទេសចរណ៍ ខណៈវិស័យកសិកម្មមានកំណើនតិចតួច។ គួរកត់សម្គាល់ថា ការរួមចំណែករបស់វិស័យឧស្សាហកម្មបានកើនដល់ ៣៨,៣% នៃផ.ស.ស. និងវិស័យសេវាកម្មបានរួមចំណែកប្រមាណ ៣៨,១% នៃផ.ស.ស. ខណៈដែលការរួមចំណែកនៃវិស័យកសិកម្មបានថយចុះមកត្រឹម ១៦% នៃផ.ស.ស.។

ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាអាចប្រឈមនឹងហានិភ័យខាងក្រៅមួយចំនួនដូចជា ការកើនឡើងនៃការប្រកួតប្រជែងលើទីផ្សារអន្តរជាតិ និងការថមថយនៃសេដ្ឋកិច្ចចិន។ ការប្រកួតប្រជែងលើទីផ្សារអន្តរជាតិរបស់កម្ពុជាអាចប្រឈមនឹងការថយចុះ ដោយសារប្រព័ន្ធអនុគ្រោះពន្ធអ្វីៗគ្រប់យ៉ាងលើកលែងអាវុធដែលធ្លាប់ទទួលបានកន្លងមក អាចនឹងត្រូវបានកាត់បន្ថយ ដោយសារកំណើនជាលំដាប់នៃចំណូលរបស់ប្រជាជនកម្ពុជា ក្នុងឋានៈជាប្រទេសចំណូលមធ្យមកម្រិតទាប។

### ២- អតិផរណា

អតិផរណាមានកម្រិតត្រឹម ១,៩% ទាបជាងឆ្នាំមុន (២,៥%) និងឆ្នាំ២០១៧ (២,៩%)។ ការថយចុះនេះគឺដោយសារការបន្តថមថយកំណើនថ្លៃក្រុមម្ហូបអាហារ ដែលមានសមាមាត្រធំជាងគេក្នុងកន្ត្រកទំនិញប្រើប្រាស់ ស្របពេលដែលមានការធ្លាក់ថ្លៃនៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ បើទោះជាអតិផរណាស្នូលបានកើនឡើងបន្តិចក៏ដោយ។

ថ្លៃក្រុមម្ហូបអាហារបានបន្តថមថយល្បឿនកំណើន ១,៩% ទាបជាងឆ្នាំមុន (២,៥%) និងឆ្នាំ២០១៧ (៣,៥%) ដែលរួមចំណែកដោយសារការឡើងថ្លៃបន្តិចនៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណរបស់ប្រទេសសំខាន់ៗដែលកម្ពុជានាំទំនិញចូល ស្របពេលអត្រាអតិផរណាថៃនិងវៀតណាមបានថយចុះពី ១,១% មក ០,៧% និង ៣,៥% មក ២,៥% រៀងគ្នា ធៀបនឹងឆ្នាំមុន ទោះវិស័យកសិកម្មក្នុងស្រុកបន្តមានកំណើនយឺតជាងឆ្នាំមុនបន្តិច។

ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានថយចុះ ១,២% បន្ទាប់ពីបានឡើងថ្លៃនៅឆ្នាំ២០១៧-២០១៨ ដោយសារការធ្លាក់ថ្លៃប្រេងនៅពិភពលោកដែលបណ្តាលមកពី៖ i/-កំណើននៃការផ្គត់ផ្គង់ពីសហរដ្ឋអាមេរិក ប្រេស៊ីល អ៊ីរ៉ាក់ និងអារ៉ាប់រួម ទោះជាក្រុមប្រទេសនាំចេញប្រេង (OPEC) បានបន្តកិច្ចព្រមព្រៀងកាត់បន្ថយការផ្គត់ផ្គង់ក៏ដោយ ii/-ភាពទន់ខ្សោយនៃតម្រូវការ ដោយសារការថមថយនៃកំណើនសេដ្ឋកិច្ចពិភពលោក និង iii/-វិធានការកាត់បន្ថយពន្ធនាំចូលប្រេងឥន្ធនៈនិងអន្តរាគមន៍ផ្សេងៗរបស់រាជរដ្ឋាភិបាលកម្ពុជា[១]។

---

[១] ថ្លៃប្រេងនៅពិភពលោកបានថយចុះ ១៣,១% ធៀបនឹងតម្លៃជាមធ្យម ៦៤,៩ ដុល្លារអាមេរិកកាលពីឆ្នាំ២០១៨ ចំណែកនៅកម្ពុជា ប្រេងសាំងមានតម្លៃជាមធ្យម ៣.៦២០ រៀលក្នុង១លីត្រ ដោយបានថយចុះប្រមាណ ៩% ធៀបនឹងឆ្នាំមុន។

អតិផរណាស្នូលកើនឡើងក្នុងកម្រិតទាប ២,៦% ធៀបនឹងឆ្នាំមុន (២,១%)។ ការកើនឡើងនេះជាចម្បងជំរុញដោយកំណើនថ្លៃក្រុមភោជនីយដ្ឋាន និងក្រុមភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ (បន្ទាប់ពីការដំឡើងពន្ធនាំចូល) គួបផ្សំនឹងការកើនឡើងបន្តិចនៃអតិផរណាក្រុមកម្សាន្តនិងវប្បធម៌ ក្រុមផ្ទះសម្បែង និងក្រុមគ្រឿងសង្ហារិមឬសម្ភារប្រើប្រាស់ក្នុងគ្រួសារនិងការថែទាំផ្ទះជាប្រចាំ។

**ក្រាហ្វ ៣ ៖ អតិផរណារួម និងការរួមចំណែកក្នុងអតិផរណារួម**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៧ - ខែធ្នូ ឆ្នាំ២០១៩)




**ក្រាហ្វ ៤ ៖ អតិផរណាតាមក្រុមសំខាន់ៗទាំងបី**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, ខែមករា ឆ្នាំ២០១៧ - ខែធ្នូ ឆ្នាំ២០១៩)




ប្រភពៈ វិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

## - អតិផរណាព្យាករណ៍ ឆ្នាំ២០២០[២]

អតិផរណាត្រូវបានព្យាករថាមានកម្រិត ២,៣% និងអតិផរណាស្នូលរំពឹងថាបន្តមានកម្រិតទាបប្រហាក់ប្រហែលនឹងកម្រិតមធ្យមក្នុងរយៈពេល៣ឆ្នាំចុងក្រោយ (២,៤%) ដែលបន្តជំរុញដោយការឡើងថ្លៃនៃក្រុមភោជនីយដ្ឋាន។

**ក្រាហ្វ ៥ ៖ អតិផរណាព្យាករណ៍**
(គិតជាភាគរយ, ឆ្នាំលើឆ្នាំ, សម្រាប់ឆ្នាំ២០២០)




ប្រភពៈវិទ្យាស្ថានជាតិស្ថិតិ និងការគណនារបស់មន្ត្រីធនាគារជាតិនៃកម្ពុជា

ការព្យាករថាអតិផរណានឹងអាចកើនឡើងបន្តិចនេះ ដោយសារ i/-ថ្លៃក្រុមម្ហូបអាហារអាចកើនឡើង (២,៥%) ដែលបណ្តាលមកពីការរំពឹងទុកថាអតិផរណាវៀតណាមនិងថៃដែលជាប្រទេសចម្បងនាំចូលម្ហូបអាហារមកកម្ពុជាកើនឡើងវិញបន្តិច និង ii/-កំណើនថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ។

[២] ការព្យាករត្រូវបានធ្វើឡើងដោយប្រើម៉ូដែល ១/- Multiple regression ដែលសិក្សាពីទំនាក់ទំនងរវាងអតិផរណា និងសូចនាករសំខាន់មួយចំនួនរួមមាន អតិផរណានៅត្រីមាសមុន អតិផរណាដែគូនាំចូល បម្រែបម្រួលថ្លៃប្រេងឥន្ធនៈពិភពលោក កំណើនឥណទាន និងបម្រែបម្រួលអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក។ ២/- ARIMA(p,d,q) ដែលធ្វើការព្យាករក្រុមទាំង ១២ នៅក្នុងកន្ត្រកទំនិញប្រើប្រាស់ ដោយផ្អែកលើតម្លៃគ្រាមុននិងគន្លងរបស់អថេរទាំងនោះ។ ៣/-VARX ដែលមានអត្រាអតិផរណា កំណើនឥណទាន បម្រែបម្រួលអត្រាប្តូរប្រាក់ អតិផរណាដៃគូនាំចូល និងដាក់ថ្លៃប្រេងជា exogenous variables។ ៤/- ARIMA (៣,១,៣) អត្រាអតិផរណាគ្រាមុនៗចំនួន ៣ ត្រីមាស និង ៥/- VARX ដែលព្យាករអតិផរណាស្នូល អតិផរណាក្រុមម្ហូបអាហារ និងអតិផរណាក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ។

## ៣- អត្រាប្តូរប្រាក់

អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបន្តមានស្ថិរភាព ជាមធ្យមប្រមាណ ៤.០៥៥ រៀលក្នុងមួយដុល្លារអាមេរិក ធៀបនឹងឆ្នាំមុន (៤.០៥១) ដោយសារការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ក្នុងបរិបទដែលតម្លៃប្រាក់រៀលបានប្រែប្រួលបន្តិចបន្តួចទៅតាមកត្តារដូវកាល ជាពិសេសកំណើនតម្រូវការប្រាក់រៀលសម្រាប់បង់ពន្ធ (កើន ២៥% ក្នុងរយៈពេល១០ខែដើមឆ្នាំ២០១៩)។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ដោយបញ្ចេញប្រាក់រៀលស្មើ ២ដងនៃទំហំក្នុងឆ្នាំ២០១៨។

**ក្រាហ្វ ៦ ៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**
(ខែមករា ឆ្នាំ២០១៥ - ខែតុលា ឆ្នាំ២០១៩)




**ក្រាហ្វ ៧ ៖ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក**
(ឆ្នាំ២០០០ -២០១៩ ព្យាករណ៍)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចូល (IREER) បានថយចុះ ០,១% ដោយសារការឡើងថ្លៃនៃប្រាក់រៀលធៀបនឹងរូបិយប័ណ្ណនៃប្រទេសមួយចំនួនដែលនាំទំនិញចូលមកកម្ពុជា (អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចូល[៣] (INEER) ថយចុះ ១,៩%) ជាពិសេស វ៉ុនកូរ៉េ យ៉ន់ចិន ដុល្លារតៃវ៉ាន់ ដុល្លារសិង្ហបុរី និងដុងវៀតណាម គួបផ្សំនឹងតម្លៃទំនិញនាំចូលមកកម្ពុជាមានកម្រិតទាបជាងមុន។ ការណ៍នេះឆ្លុះបញ្ចាំងឱ្យឃើញថា កម្ពុជាមិនទទួលរងសម្ពាធអតិផរណានាំចូលទេ។

អត្រាប្តូរប្រាក់ប្រសិទ្ធភាពពិតថ្លឹងតាមការនាំចេញ (EREER) បានថយចុះប្រមាណ ១,៩% ដោយសារប្រាក់រៀលបានឡើងថ្លៃបន្តិចធៀបនឹងរូបិយប័ណ្ណនៃប្រទេសដៃគូនាំចេញ ជាពិសេសប្រាក់អឺរ៉ូ ផោនអង់គ្លេស យ៉ន់ចិន និង ដុល្លារកាណាដា (អត្រាប្តូរប្រាក់ប្រសិទ្ធភាពនាមនាមថ្លឹងតាមការនាំចេញ (ENEER) បានថយចុះ ១,៣%)។ ទន្ទឹមនេះ ថ្លៃទំនិញក្នុងប្រទេសជាគោលដៅនាំចេញក៏បានថយចុះផងដែរ។ ការណ៍នេះ បានដាក់សម្ពាធលើឧត្តមភាពប្រកួតប្រជែងនៃការនាំចេញ[៤]របស់កម្ពុជា។

[៣] ប្រទេសដៃគូនាំចូលមកកម្ពុជាចម្បងៗរួមមាន៖ ចិន ថៃ វៀតណាម តៃវ៉ាន់ សិង្ហបុរី ជប៉ុន ហុងកុង កូរ៉េ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងសហរដ្ឋអាមេរិក។

[៤] ប្រទេសគោលដៅនាំចេញរបស់កម្ពុជាជាចម្បងៗរួមមាន៖ សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស អាល្លឺម៉ង់ ជប៉ុន កាណាដា ចិន ថៃ អេស្ប៉ាញ បែលហ្ស៊ិក បារាំង ហូឡង់ វៀតណាម ហុងកុង និងអ៊ីតាលី។

**ក្រាហ្វ ៨ ៖ អន្តរាគមន៍លើទីផ្សារប្តូរប្រាក់**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០១៣ - ២០១៩ ព្យាករណ៍)




**ក្រាហ្វ ៩ ៖ អត្រាប្តូរប្រាក់ប្រសិទ្ធភាព**
(គិតជាសន្ទស្សន៍, សន្ទស្សន៍គោល ខែធ្នូ ឆ្នាំ២០១០, ឆ្នាំ២០១៣ - ២០១៩ ព្យាករណ៍)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៤- ស្ថានភាពជញ្ជីងទូទាត់[៥]

ក្នុងរយៈពេល៩ខែដើមឆ្នាំនេះ ជញ្ជីងទូទាត់មានអតិរេក ១០,៥% នៃផ.ស.ស. (២,១ ប៊ីលានដុល្លារអាមេរិក) ធៀបនឹង ៣,៩% នៃផ.ស.ស. ក្នុងគ្រាដូចគ្នាឆ្នាំ២០១៨ ដែលគាំទ្រដោយអតិរេកគណនីហិរញ្ញវត្ថុ។ សម្រាប់ឆ្នាំ២០១៩ ជញ្ជីងទូទាត់នឹងបន្តមានអតិរេក ៩,៦% នៃផ.ស.ស. (២,៦ ប៊ីលានដុល្លារអាមេរិក) ធៀបនឹង ៥,៩% ក្នុងគ្រាដូចគ្នាឆ្នាំមុន ដែលគាំទ្រដោយភាពរឹងមាំនៃលំហូរទុនវិនិយោគផ្ទាល់បរទេស កំណើនភ្ញៀវទេសចរបរទេសនិងការនាំចេញ។

**ក្រាហ្វ ១០ ៖ ជញ្ជីងទូទាត់កម្ពុជា**
(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០០៩ - ២០១៩ ប៉ាន់ស្មាន)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

- **គណនីចរន្ត និងដើមទុន**

៩ខែដើមឆ្នាំនេះ ឱនភាពគណនីចរន្តមានសមាមាត្រ ១៦,៦% នៃផ.ស.ស. (៣,៤ ប៊ីលានដុល្លារអាមេរិក) ធៀបនឹង ១១,៦% នៃផ.ស.ស. គ្រាដូចគ្នាឆ្នាំមុន ដោយសារកំណើនឱនភាពពាណិជ្ជកម្មទំនិញ និងចំណូលបឋម ខណៈភាពប្រសើរឡើងនៃអតិរេកគណនីសេវា និងប្រាក់ចំណូលបន្ទាប់បន្សំបានជួយជាត់ទាត់មួយផ្នែកនៃឱនភាពនេះ។ ដោយឡែក គណនីដើមទុនមានលំហូរចូលទាបជាងគ្រាដូចគ្នាឆ្នាំមុន។ សម្រាប់ឆ្នាំ២០១៩នេះ គណនីចរន្តត្រូវបានប៉ាន់ស្មានថាមានឱនភាព ១៥,៧% នៃផ.ស.ស. (៤,២ ប៊ីលានដុល្លារអាមេរិក) ដោយកើនឡើងប្រមាណ ៣,៥% នៃផ.ស.ស. ធៀបនឹងឆ្នាំ២០១៨ (១២,២% នៃផ.ស.ស.) ខណៈគណនីដើមទុននឹងទទួលបានលំហូរចូល ១៩៤ លានដុល្លារអាមេរិក។

[៥] ស្ថិតិជញ្ជីងទូទាត់កម្ពុជាត្រូវបានចងក្រងផ្អែកតាមវិធីសាស្រ្តចងក្រងស្ថិតិជញ្ជីងទូទាត់បោះពុម្ពលើកទី៦ (BPM6) របស់មូលនិធិរូបិយវត្ថុអន្តរជាតិ។

**ក្រាហ្វ ១១ ៖ គណនីចរន្ត និងដើមទុន**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០០៩ - ២០១៩ ប៉ាន់ស្មាន)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

គិតត្រឹម៩ខែ ជញ្ជីងពាណិជ្ជកម្មទំនិញបន្តមានឱនភាព និងបានកើនឡើងដល់ ២៧,៦% នៃ ផ.ស.ស. ធៀបនឹង ២២,៥% នៃផ.ស.ស. គ្រាដូចគ្នាឆ្នាំមុន ដែលបណ្តាលមកពីកំណើននៃការនាំចូលលឿនជាងកំណើននៃការនាំចេញ។ ការនាំចូលសរុប បានកើនឡើង ១៨% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (២២%) ជាចម្បងដោយសារកំណើនការនាំចូលប្រេងឥន្ធនៈ (៦៨%) យានយន្ត (៤៧%) សម្ភារសំណង់[៦] (៥១%) ទោះបីជាវត្ថុធាតុដើមសម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើងបានថយចុះ ៥% (ធៀបនឹងការកើនឡើង ២៤% នៃគ្រាដូចគ្នាឆ្នាំមុន)។ ការនាំចេញសរុបបានកើនឡើង ១១% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន (១៨%) ជាចម្បងបណ្តាលមកពីការកើនឡើងការនាំចេញផលិតផលកាត់ដេរ[៧] (៩%) ផលិតផលកម្មន្តសាលក្រៅពីកាត់ដេរ[៨] (២២%) អង្ករ[៩] (៤%) និងកៅស៊ូ (២%)។

ក្រៅពីឱនភាពជញ្ជីងពាណិជ្ជកម្មទំនិញ ការកើនឡើងឱនភាពចំណូលបឋម (០,២% នៃផ.ស.ស) និងការថយចុះអតិរេកចំណូលបន្ទាប់បន្សំ (១,២% នៃផ.ស.ស.) ក៏បានរួមចំណែកក្នុងការកើនឡើងឱនភាពគណនីចរន្តផងដែរ ខណៈភាពប្រសើរឡើងនៃអតិរេកគណនីសេវាសុទ្ធ (១,៩% នៃផ.ស.ស.) បានជួយផាត់ទាត់មួយផ្នែកលើឱនភាពនេះ។

- **គណនីហិរញ្ញវត្ថុ**

លំហូរចូលរឹងមាំពីការវិនិយោគផ្ទាល់បរទេសបានជួយឱ្យគណនីហិរញ្ញវត្ថុបន្តមានអតិរេក ដែលបានផាត់ទាត់ឱនភាពគណនីចរន្តទាំងស្រុង ព្រមទាំងជួយគរពូនទុនបម្រុងអន្តរជាតិឱ្យកើនឡើងជាលំដាប់។ លំហូរវិនិយោគផ្ទាល់បរទេសក្នុងរយៈពេល៩ខែដើមឆ្នាំ មានសមាមាត្រ ១៣,៣% នៃ ផ.ស.ស. ធៀបនឹង ១២,៩% គ្រាដូចគ្នាឆ្នាំមុន ដែលគាំទ្រដោយការវិនិយោគផ្ទាល់បរទេសក្នុងវិស័យធនាគារ សំណង់ និងអចលនទ្រព្យ។ ទន្ទឹមនេះ ការវិនិយោគលើវិស័យកម្មន្តសាល និងវិស័យកាត់ដេរ

---

[៦] នាំចូលបរិក្ខារសំណង់បានកើនឡើង ៤២% ដែក ៤៧% និងស៊ីម៉ងត៍ ៨៣%។

[៧] ការនាំចេញសម្លៀកបំពាក់បានកើនឡើង ៤% ស្បែកជើង ១៩% និងវាយនភ័ណ្ឌផ្សេងទៀត ១១៧% ដែលគាំទ្រដោយទីផ្សារសហរដ្ឋអាមេរិក អឺរ៉ុប និងជប៉ុន ខណៈដែលទីផ្សារ អាស៊ាន និងអង់គ្លេសបានថយចុះ។

[៨] ការនាំចេញសម្ភារអគ្គិសនីបានកើនឡើង ៦៥% គ្រឿងបន្លាស់យានយន្ត ៥២% និងទោចក្រយាន ២%។

[៩] ការនាំចេញអង្ករគិតជាតម្លៃបានកើនឡើង ៤% (ជាបរិមាណថយចុះ ៤%) គាំទ្រដោយទីផ្សារអាស៊ាន និងទីផ្សារផ្សេងទៀត ខណៈដែលការនាំចេញទៅទីផ្សារអឺរ៉ុបបានថយចុះ ២៣% និងអង់គ្លេសថយចុះ ៣២% បន្ទាប់ពីសហភាពអឺរ៉ុបយកពន្ធលើការនាំចូលអង្ករពីកម្ពុជាចាប់តាំងពីដើមឆ្នាំ២០១៩។

សម្លៀកបំពាក់និងស្បែកជើងនៅតែមានចំណែកធំ ស្របពេលដែលការធ្វើពិពិធកម្មក្នុងវិស័យនេះបានកើនឡើងគួរកត់សម្គាល់។ សម្រាប់ឆ្នាំនេះ គណនីហិរញ្ញវត្ថុត្រូវបានប៉ាន់ស្មានថាកើនឡើងប្រមាណ ៨% នៃផ.ស.ស. ធៀបនឹង ២,១% គ្រាដូចគ្នាឆ្នាំមុន គាំទ្រដោយវិនិយោគផ្ទាល់បរទេសជាពិសេសក្នុងវិស័យធនាគារ កម្មន្តសាល និងអចលនទ្រព្យនិងសំណង់។

សម្រាប់ឆ្នាំ២០២០ ស្ថានភាពជញ្ជីងទូទាត់ត្រូវបានព្យាករថានឹងមានអតិរេកក្នុងកម្រិត ៦,៥% នៃផ.ស.ស. ដែលគាំទ្រដោយលំហូរវិនិយោគផ្ទាល់បរទេស ការនាំចេញ និងវិស័យទេសចរណ៍។

**ក្រាហ្វ ១២ ៖ គណនីហិរញ្ញវត្ថុ**

(គិតជាលានដុល្លារអាមេរិក, ឆ្នាំ២០០៩ - ២០១៩ ប៉ាន់ស្មាន)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ៥- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

អតិរេកជញ្ជីងទូទាត់បានបន្តរួមចំណែកបង្កើនទុនបម្រុងអន្តរជាតិដុល[10]ដល់ប្រមាណ ១៨ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាលើការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់បានជាង ៧ខែ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍[11]។

**ក្រាហ្វ ១៣ ៖ ទុនបម្រុងអន្តរជាតិ និងចំនួនខែនៃការនាំចូលទំនិញនិងសេវាគ្រាបន្ទាប់**

(ឆ្នាំ២០០៧- ២០១៩ប៉ាន់ស្មាន)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[10] ទុនបម្រុងអន្តរជាតិជាទ្រព្យសកម្មបរទេសដែលគ្រប់គ្រងដោយធនាគារជាតិនៃកម្ពុជា រួមមាន មាស SDR និងរូបិយប័ណ្ណបរទេស (ដែលរក្សាទុកនៅបរទេសនិងនៅធនាគារជាតិនៃកម្ពុជា)។

[11] សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍គឺ ៣ខែ

ទុនបម្រុងអន្តរជាតិត្រូវបានវិនិយោគ ដោយគោរពតាមសេចក្តីណែនាំការវិនិយោគទុនបម្រុងអន្តរជាតិឆ្នាំ២០១៩ និងស្របតាមនិន្នាការទីផ្សារហិរញ្ញវត្ថុអន្តរជាតិនាពេលបច្ចុប្បន្ន។ ម៉្យាងទៀត ទុនបម្រុងអន្តរជាតិត្រូវបានវិនិយោគក្រោមរូបភាពជាអូវើណាយ ប្រាក់បញ្ញើរយៈពេលខ្លី ឧបករណ៍ហិរញ្ញវត្ថុរយៈពេលមធ្យម សញ្ញាប័ណ្ណ (រដ្ឋាភិបាល ភ្នាក់ងាររដ្ឋាភិបាល និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ) និងបញ្ញើជាមាសជាមួយធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍ និងគ្រឹះស្ថានធនាគារពាណិជ្ជអន្តរជាតិដែលមានក្រេឌីតរ៉េតទីងខ្ពស់។

ជាទូទៅ ការគ្រប់គ្រងទុនបម្រុងអន្តរជាតិអាចប្រឈមនឹងហានិភ័យសំខាន់ៗដូចជា ហានិភ័យទីផ្សារ ហានិភ័យសន្ទនីយភាព ហានិភ័យឥណទាន និងហានិភ័យប្រតិបត្តិការ។ ដើម្បីធានាបាននូវសុវត្ថិភាពនិងប្រសិទ្ធភាព ការវិនិយោគទុនបម្រុងអន្តរជាតិត្រូវបានធ្វើឡើង ដោយគោរពតាមគោលការណ៍អាទិភាពបីគឺ៖ i/-ការរក្សាដើមទុន ii/-សន្ទនីយភាព និង iii/-ចំណូល។ ជាងនេះទៀត ការវិនិយោគទុនបម្រុងអន្តរជាតិក៏ត្រូវបានយកចិត្តទុកដាក់លើគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ផងដែរ ដោយមិនត្រូវបានអនុញ្ញាតឱ្យវិនិយោគលើសញ្ញាប័ណ្ណសាជីវកម្មដែលពាក់ព័ន្ធនឹងការបំពុលបរិស្ថាន អាវុធជាតិផ្ទុះ និងគ្រឿងស្រវឹង ដើម្បីបញ្ចៀសហានិភ័យពាក់ព័ន្ធផ្សេងៗ ដូចជាហានិភ័យកេរ្តិ៍ឈ្មោះ និងហានិភ័យផ្លូវច្បាប់ជាដើម។

## III- ការគ្រប់គ្រងរូបិយវត្ថុ

### ១- ស្ថានភាពរូបិយវត្ថុ

រូបិយវត្ថុទូទៅ (M2)[១២] មានកំណើន ១៩,១% (ឆ្នាំលើឆ្នាំ) ទាបជាងឆ្នាំ២០១៨ (២៤%) និងកំណើនជាមធ្យម ៥ ឆ្នាំចុងក្រោយ (២១,៤%) ដែលជាកម្រិតសមស្របនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ។ ការកើនឡើងនេះគាំទ្រជាចម្បងដោយកំណើនប្រាក់បញ្ញើជារូបិយប័ណ្ណ ១៦,៤% (ទាបជាងឆ្នាំមុន ២៦,៥%) ប្រាក់បញ្ញើជាប្រាក់រៀល ៣៧% (ខ្ពស់ជាងឆ្នាំមុន ១២%) និងរូបិយវត្ថុក្នុងចរាចរណ៍ ៣៣% (ខ្ពស់ជាងឆ្នាំមុន ១២%)។ ទន្ទឹមនេះ កំណើនរូបិយវត្ថុទូទៅ បានធ្វើឱ្យភាពស៊ីជម្រៅផ្នែកហិរញ្ញវត្ថុ (M2/GDP) កើនឡើងដល់ ៩៦,៤% ខ្ពស់ជាងគ្រាដូចគ្នាឆ្នាំមុន (៨៨,៨%)។

**ក្រាហ្វ ១៤ ៖ រូបិយវត្ថុទូទៅ** (M2)

(គិតជាទ្រីលានរៀល ឆ្នាំ២០១០ - ឆ្នាំ២០១៩ ព្យាករណ៍)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[១២] រូបិយវត្ថុទូទៅ (M2) = រូបិយវត្ថុ M1 (រូបិយវត្ថុក្នុងចរាចរណ៍ និងប្រាក់បញ្ញើចរន្តជារៀល) + រូបិយវត្ថុផ្សេងៗ (Quasi Money ដែលរួមមានប្រាក់បញ្ញើមានកាលកំណត់និងសន្សំជារៀល និងប្រាក់បញ្ញើជារូបិយប័ណ្ណគ្រប់ប្រភេទរបស់និវាសជន ដែលជាទូទៅអាចបំប្លែងទៅជាសាច់ប្រាក់យឺតជាងរូបិយវត្ថុ M1 ក្នុងការប្រើប្រាស់សម្រាប់ទូទាត់)។

ចំណែកឯ ដុល្លារូបនីយកម្មនៅតែបន្តមានកម្រិតខ្ពស់ ដែលឆ្លុះបញ្ចាំងតាមរយៈអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងរូបិយវត្ថុទូទៅដែលមានកម្រិត ៨២,៩% (ទាបជាងឆ្នាំមុន ៨៤,៨%) និងអនុបាតប្រាក់បញ្ញើជារូបិយប័ណ្ណធៀបនឹងប្រាក់បញ្ញើសរុបមានកម្រិត ៩៣,៩% (ប្រហាក់ប្រហែលឆ្នាំមុន ៩៤,៧%)។ កម្រិតខ្ពស់នៃដុល្លារូបនីយកម្មបណ្តាលមកពីលំហូរចូលនៃប្រាក់ដុល្លារអាមេរិកដែលត្រូវបានប្រើប្រាស់ដោយផ្ទាល់ក្នុងប្រតិបត្តិការសេដ្ឋកិច្ច ជាពិសេសតាមរយៈពាណិជ្ជកម្ម ការវិនិយោគ ទេសចរណ៍ និងការផ្ទេរប្រាក់ផ្សេងៗ។

## ប្រអប់ ២ ៖ ស្ថានភាពសន្ទនីយភាព

សន្ទនីយភាពក្នុងប្រព័ន្ធធនាគារបន្តស្ថិតក្នុងកម្រិតខ្ពស់ ដែលបង្ហាញពីភាពធន់នៃប្រព័ន្ធធនាគារទល់នឹងហានិភ័យសន្ទនីយភាពដែលអាចកើតឡើងជាយថាហេតុ ប៉ុន្តែក៏បានបង្ហាញពីកង្វះប្រសិទ្ធភាពនៃការគ្រប់គ្រងសន្ទនីយភាពរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំពោះសាច់ប្រាក់ដែលនៅសល់។ នៅឆ្នាំ២០១៩នេះ សន្ទនីយភាពលើស[១៣]ជាដុល្លារអាមេរិកមាន ២,៥ ប៊ីលានដុល្លារអាមេរិក កើន ៣១,៨% (ខ្ពស់ជាងឆ្នាំមុន ១៣,៤% និងមធ្យម៥ឆ្នាំ ២២,៦%) និងមានកម្រិតស្មើនឹង ៦៧,២% នៃប្រាក់បម្រុងកាតព្វកិច្ចជាដុល្លារអាមេរិក (ខ្ពស់ជាងឆ្នាំមុន ៦១,១%)។ ចំណែកឯសន្ទនីយភាពលើសជារៀលមាន ២,៥ ទ្រីលានរៀល កើន ៣២% (ប្រហាក់ប្រហែលឆ្នាំមុន ៣២,៨% ប៉ុន្តែខ្ពស់ជាងមធ្យម៥ឆ្នាំ ២៥,៦%) និងស្មើនឹង ៣,៧ដង នៃប្រាក់បម្រុងកាតព្វកិច្ចជារៀល (ប្រហាក់ប្រហែលឆ្នាំមុន ៣,៥ដង)។ កំណើនខ្ពស់នេះដោយសារមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបើកថ្មីដែលធ្វើឱ្យប្រាក់បម្រុងសរុបក្នុងប្រព័ន្ធធនាគារកើនឡើង។

**អនុបាតប្រាក់បម្រុងលើសធៀបនឹងប្រាក់បម្រុងកាតព្វកិច្ច**
(គិតជាភាគរយ, ឆ្នាំ២០១២ - ២០១៩ ព្យាករណ៍)




**បម្រែបម្រួលប្រាក់បម្រុងលើស**
(ឆ្នាំ២០១៣ - ២០១៩ ព្យាករណ៍)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

---

[១៣] សន្ទនីយភាពលើស (ប្រាក់បម្រុងលើស) = ប្រាក់បម្រុងសរុប - ប្រាក់បម្រុងកាតព្វកិច្ច

## ២- ឧបករណ៍គោលនយោបាយរូបិយវត្ថុ

### ក- អត្រាប្រាក់បម្រុងកាតព្វកិច្ច

ធនាគារជាតិនៃកម្ពុជាបានបន្តរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ចជារៀល (៨%) ទាបជាងដុល្លារអាមេរិក (១២,៥%) ដើម្បីលើកទឹកចិត្តនិងជំរុញឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកេណ្ឌប្រមូលប្រាក់បញ្ញើ និងផ្តល់ឥណទានជារៀល។

**ក្រាហ្វ ១៥ ៖ ទំហំនិងអត្រាប្រាក់បម្រុងកាតព្វកិច្ច**

(ឆ្នាំ១៩៩៣ - ខែវិច្ឆិកា ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### ខ- មូលបត្រអាចជួញដូរបាន (NCD)

ការចេញផ្សាយមូលបត្រអាចជួញដូរបាន (NCD) ចារឹកជាដុល្លារអាមេរិកនិងជារៀលក្នុងរយៈពេល៣ឆ្នាំចុងក្រោយបានកើនឡើងគួរឱ្យកត់សម្គាល់ ចាប់តាំងពីការបោះផ្សាយដំបូងក្នុងឆ្នាំ២០១៣។ ទោះយ៉ាងណា ក្នុងឆ្នាំ២០១៩នេះ ការចេញផ្សាយ NCD បានធ្លាក់ចុះបន្តិច បើធៀបនឹងឆ្នាំមុន។

គិតត្រឹមខែវិច្ឆិកាឆ្នាំនេះ ការចេញផ្សាយ NCD ចារឹកជាដុល្លារអាមេរិកបានថយចុះ ៨%[១៤] ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ដោយសារការកើនឡើងនៃតម្រូវការប្រាក់ដុល្លារអាមេរិកដើម្បីទិញប្រាក់រៀលពីធនាគារជាតិនៃកម្ពុជាសម្រាប់កំណើនតម្រូវការបង់ពន្ធ។ ទន្ទឹមនេះ NCD ចារឹកជារៀលបានថយចុះ ៧%[១៥] ដោយសារការកើនឡើងនៃតម្រូវការប្រាក់រៀលដើម្បីអនុវត្តតាមប្រកាសដែលតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានឥណទានជារៀលយ៉ាងតិច ១០% នៃសំពៀតឥណទានសរុប។ ជាលទ្ធផល NCD បានស្រូបយកសន្ទនីយភាពលើសជាដុល្លារអាមេរិកចំនួន ៤៩% (ទាបជាងឆ្នាំមុន ៥៦%) និងជារៀល ១០,៥% (ទាបជាងឆ្នាំមុន ៣២%)។ សម្រាប់ឆ្នាំ២០១៩ ការចេញផ្សាយ NCD ចារឹកជាដុល្លារអាមេរិកនិងជារៀលត្រូវបានប៉ាន់ស្មានថាថយចុះ ១២% និង ៩% រៀងគ្នា។

ដើម្បីបង្កើនភាពទាក់ទាញលើ NCD ធនាគារជាតិនៃកម្ពុជាបានដំឡើងអត្រាការប្រាក់ NCD ចារឹកជាដុល្លារអាមេរិកចំនួន ០,២៥% សម្រាប់ឥណប្រតិទាន ៩១ថ្ងៃ, ១៨២ថ្ងៃ, និង៣៦៤ថ្ងៃ ចាប់ពីខែមីនា និងដំឡើង ០,១០% បន្ថែមទៀត សម្រាប់គ្រប់ឥណប្រតិទាន ចាប់ពីខែតុលា។ ទោះយ៉ាងណាអត្រាការប្រាក់ NCD ក្នុងឆ្នាំនេះមានកម្រិតទាបជាងអត្រាការប្រាក់កាលពីឆ្នាំមុនដោយសារតែអត្រា LIBOR មាននិន្នាការថយចុះជាបន្តបន្ទាប់ចាប់តាំងពីដើមឆ្នាំមក។

---

[១៤] ទំហំចេញផ្សាយ ១៩,៣ ប៊ីលានដុល្លារអាមេរិក

[១៥] ទំហំចេញផ្សាយ ៩,៥ ទ្រីលានរៀល

**ក្រាហ្វ ១៦ ៖ អត្រាការប្រាក់ NCD ចារឹកជាដុល្លារអាមេរិក**
(អត្រាមធ្យម, ខែមករា-វិច្ឆិកា ឆ្នាំ២០១៧, ២០១៨, ២០១៩)




**ក្រាហ្វ ១៧ ៖ អត្រាការប្រាក់ NCD ចារឹកជារៀល**
(អត្រាមធ្យម, ខែមករា-វិច្ឆិកា ឆ្នាំ២០១៧, ២០១៨, ២០១៩)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ១៨ ៖ NCD ចារឹកជាដុល្លារអាមេរិកដែលបានចេញផ្សាយនិងមិនទាន់ដល់ឥណប្រតិទាន**
(ឆ្នាំ២០១៣ - ២០១៩ ព្យាករណ៍)




**ក្រាហ្វ ១៩ ៖ NCD ចារឹកជារៀលដែលបានចេញផ្សាយនិងមិនទាន់ដល់ឥណប្រតិទាន**
(ឆ្នាំ២០១៤ - ២០១៩ ព្យាករណ៍)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

### គ- ប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)

ទំហំប្រតិបត្តិការ LPCO បានកើនឡើងគួរឱ្យកត់សម្គាល់ ដោយសារកំណើនតម្រូវការប្រាក់រៀលលើទីផ្សារ ស្របពេលដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកំពុងបង្កើនសំពៀតឥណទានជារៀលឱ្យបានយ៉ាងតិច ១០%។ ដើម្បីឆ្លើយតបនឹងកំណើនតម្រូវការនេះ ទំហំទឹកប្រាក់ដាក់ឱ្យដេញថ្លៃក្នុងមួយលើកៗត្រូវបានកែប្រែជាបន្តបន្ទាប់ ដោយបានដំឡើងពី ១០០ ប៊ីលានរៀល មក ២០០ ប៊ីលានរៀល និងបន្ទាប់មក ៤០០ ប៊ីលានរៀល ហើយចាប់ពីខែមេសា ប្រតិបត្តិការត្រូវបានធ្វើឡើង២ដងក្នុង១ខែ ដើម្បីឱ្យការស្នើសុំសន្ទនីយភាពកាន់តែមានភាពបត់បែននិងទាន់ពេលវេលា។ ជាលទ្ធផល គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៩ ទំហំទឹកប្រាក់ស្នើសុំដេញថ្លៃសរុបមាន ៥,៨ ទ្រីលានរៀល (កើន ៦,៣ដង ធៀបនឹងឆ្នាំ២០១៨ និង ៩២,៥ដង ធៀបនឹងឆ្នាំ២០១៧) រីឯទំហំទឹកប្រាក់ដេញថ្លៃបានជោគជ័យសរុបមាន ៣,៤ ទ្រីលានរៀល (កើន ៣,៩ដង ធៀបនឹងឆ្នាំ២០១៨ និង ២៤,៦ដង ធៀបនឹងឆ្នាំ២០១៧)។ ជាមធ្យម អត្រាការប្រាក់ LPCO ក្នុងឆ្នាំនេះមានកម្រិត ២,៦១% ២,៨៥% និង ៣,០៨% សម្រាប់ប្រភេទឥណប្រតិទាន ៩១ថ្ងៃ ១៨២ថ្ងៃ និង៣៦៤ថ្ងៃ រៀងគ្នា។

**ក្រាហ្វ ២០ ៖ ទំហំទឹកប្រាក់ក្នុងប្រតិបត្តិការ LPCO**
(គិតជាប៊ីលានរៀល, ខែតុលា ឆ្នាំ២០១៦ - ខែវិច្ឆិកា ឆ្នាំ២០១៩)




**ក្រាហ្វ ២១ ៖ ទំហំទឹកប្រាក់មិនទាន់ដល់ឥណប្រតិទាន**
(គិតជាប៊ីលានរៀល, ខែតុលា ឆ្នាំ២០១៦ -ខែវិច្ឆិកា ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ប្រអប់ ៣ ៖ ការអភិវឌ្ឍទីផ្សារអន្តរធនាគារកម្ពុជា

(សេចក្តីសង្ខេបអត្ថបទស្រាវជ្រាវក្រោមប្រធានបទ "ការអភិវឌ្ឍទីផ្សារអន្តរធនាគារនៅកម្ពុជា")

ការអភិវឌ្ឍទីផ្សារអន្តរធនាគារចាប់ផ្តើមឡើងនៅដើមទសវត្សរ៍ឆ្នាំ២០០០ ហើយច្បាប់ស្តីពី "ឧបករណ៍អាចជួញដូរបាននិងប្រតិបត្តិការទូទាត់សងប្រាក់" ត្រូវបានដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០០៥ ដែលជាមូលដ្ឋានសម្រាប់ដាក់ឱ្យប្រើប្រាស់នូវឧបករណ៍គោលនយោបាយរូបិយវត្ថុចំនួន ២ គឺ មូលប័ត្រអាចជួញដូរបាន (NCD) និងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO)។ ទោះយ៉ាងណា សន្ទនីយភាពលើសក្នុងប្រព័ន្ធធនាគារកម្ពុជានៅបន្តមានកម្រិតខ្ពស់។ នៅឆ្នាំ ២០១៩នេះ អនុបាតនៃប្រាក់បម្រុងលើសសរុបធៀបនឹងប្រាក់បម្រុងកាតព្វកិច្ចសរុបមានប្រមាណ ៨០% ដែលអាចបង្ហាញជារួមថា៖ ១/-ប្រព័ន្ធធនាគារទាំងមូលអាចមានភាពធន់នឹងហានិភ័យកង្វះសន្ទនីយភាព ឬ ២/- ប្រព័ន្ធធនាគារអាចកំពុងប្រឈមនឹងបញ្ហាក្នុងការគ្រប់គ្រងលំហូរសន្ទនីយភាព។

ដើម្បីស្វែងយល់ឱ្យបានច្បាស់ នៅឆ្នាំ២០១៩នេះ ធនាគារជាតិនៃកម្ពុជាសហការជាមួយធនាគារកណ្តាលកូរ៉េ ក្រោមកម្មវិធី "ភាពជាដៃគូផ្តល់ចំណេះដឹង" បានធ្វើការស្រាវជ្រាវរួមគ្នាមួយក្រោមប្រធានបទ "ការអភិវឌ្ឍទីផ្សារអន្តរធនាគារនៅកម្ពុជា"។ ការសិក្សាបានបង្ហាញពីបញ្ហាប្រឈមនិងដំណោះស្រាយជាគោលនយោបាយសំខាន់ៗមួយចំនួន៖

**១.បញ្ហាប្រឈម**

- កង្វះជំនឿទុកចិត្តក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ
- អវត្តមាននៃឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចជា ប័ណ្ណបំណុលរដ្ឋាភិបាលជាដើម
- ហេដ្ឋារចនាសម្ព័ន្ធទីផ្សារអន្តរធនាគារនៅមានកម្រិត ថ្វីបើច្បាប់បទប្បញ្ញត្តិ និងផ្លែតហ្វមសម្រាប់ដំណើរការទីផ្សារអន្តរធនាគារត្រូវបានដាក់ចេញជាបន្តបន្ទាប់ក៏ដោយ។

**២.ដំណោះស្រាយជាគោលនយោបាយ**

- កសាងទំនុកចិត្តក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ និងបង្កើតឱ្យមានប័ណ្ណបំណុលរដ្ឋាភិបាល គឺជាជំហានសំខាន់ដើម្បីកែលម្អទីផ្សារអន្តរធនាគារដែលអសកម្មបច្ចុប្បន្ន។
- បង្កើតឈ្មួញជើងសារក្នុងទីផ្សារអន្តរធនាគារ។ ដោយសារទំហំប្រតិបត្តិការក្នុងទីផ្សារអន្តរធនាគារនៅមានទំហំតូច ដែលពុំអាចផ្តល់កម្រៃជើងសារគ្រប់គ្រាន់ដល់ភ្នាក់ងារជើងសារ ធនាគារជាតិនៃ

កម្ពុជាអាចជួយសម្រួល តាមរយៈការបង្កើតក្រុមការងារមួយដែលដើរតួនាទីជាភ្នាក់ងារជើងសារ ដើម្បីជួយផ្គូរផ្គងតម្រូវការរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានបំណងចង់ផ្គត់ផ្គង់ ឬស្វែងរកមូលនិធិនៅលើទីផ្សារអន្តរធនាគារ។
- សមាគមមីក្រូហិរញ្ញវត្ថុក៏អាចដើរតួនាទីជាឈ្មួញជើងសារ ឬផ្តល់ការធានាដល់កម្ចីរបស់ស្ថាប័នដែលជាសមាជិករបស់ខ្លួនដើម្បីបង្កើននូវទំនុកចិត្តរវាងគ្រឹះស្ថានហិរញ្ញវត្ថុ។
- រឹតបន្តឹងបទប្បញ្ញត្តិលើស្ថាប័នមីក្រូហិរញ្ញវត្ថុនិងគ្រឹះស្ថានធនាគារតូចៗ ដោយបង្កើនការប្រុងប្រយ័ត្នក្នុងការផ្តល់កម្ចីដល់វិស័យដែលមានហានិភ័យខ្ពស់។
- អភិវឌ្ឍបន្ថែមនូវផ្លេតហ្វមរបស់ធនាគារជាតិក្នុងគោលដៅធ្វើឱ្យគ្រឹះស្ថានហិរញ្ញវត្ថុអាចធ្វើប្រតិបត្តិការដោះដូរជាមួយគ្នាដោយផ្ទាល់ និងកាន់តែមានភាពរលូនជាងមុន។

### ប្រអប់ ៤ ៖ ការអភិវឌ្ឍនៃសញ្ញាប័ណ្ណសាជីវកម្ម

គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៩ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន៧បានទទួលការអនុញ្ញាតបោះផ្សាយសញ្ញាប័ណ្ណសាជីវកម្ម ក្នុងទំហំទឹកប្រាក់សរុប ១.០០៨ ប៊ីលានរៀល។ វិនិយោគិនលើសញ្ញាប័ណ្ណទាំងនេះជា ធនាគារពាណិជ្ជ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង សាធារណជន និងមូលនិធិវិនិយោគធានារ៉ាប់រងលើឥណទាន (CGIF)។ ក្នុងនោះ វិនិយោគិនក្នុងស្រុកវិនិយោគប្រមាណ ៣៣% និង ៦៧% ទៀតជាការវិនិយោគបរទេស។

| គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ | ទំហំសាច់ប្រាក់ (គិតជាប៊ីលានរៀល) | គិតត្រឹមចុងឆ្នាំ២០១៩ |
|---|---|---|
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ | ១២០ | បានបោះផ្សាយ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអិលអូអិលស៊ី | ៨០ | បានបោះផ្សាយ |
| ធនាគារវឌ្ឍនៈអាស៊ី | ១២៨ | បានបោះផ្សាយ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ | ៤០០ | គ្រោងនឹងបោះផ្សាយ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអេអឹមខេ | ១២០ | គ្រោងនឹងបោះផ្សាយ |
| ធនាគារស្ថាបនា | ៨០ | គ្រោងនឹងបោះផ្សាយ |
| ធនាគារភ្នំពេញពាណិជ្ជ | ៨០ | គ្រោងនឹងបោះផ្សាយ |
| សរុប | ១.០០៨ | |

ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## IV- ស្ថានភាពប្រព័ន្ធធនាគារនៅកម្ពុជា

### ១- ស្ថានភាពទូទៅ

ការរីកចម្រើនគ្រប់វិស័យនៃសេដ្ឋកិច្ច និងស្ថិរភាពនយោបាយ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការបង្កើនជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគិនបរទេស ក៏ដូចជាការពង្រឹងភាពរឹងមាំ និងសុខុមាលភាពមកលើប្រព័ន្ធធនាគារនៅកម្ពុជា។ គិតត្រឹមចុងឆ្នាំ២០១៩ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុរួមមាន ធនាគារពាណិជ្ជ ៤៦ ធនាគារឯកទេស ១៥ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើ ៧៥ គ្រឹះស្ថានឥណទានជនបទ ២៤៨ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ១៥ និងគ្រឹះស្ថានផ្តល់សេវាទូទាត់ ២០។

ប្រព័ន្ធធនាគារនៅកម្ពុជាមានទំហំនិងវិសាលភាពសេវាកម្មកាន់តែធំក្នុងសេដ្ឋកិច្ច ដោយទ្រព្យសកម្មរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនឡើង ២៥,៥% ដល់ ២០៨,២ ទ្រីលានរៀល (៥០,៨ ប៊ីលានដុល្លារអាមេរិក) ដែលរួមចំណែកដោយឥណទាន ១៣១,៩ ទ្រីលានរៀល (៣២ ប៊ីលានដុល្លារអាមេរិក) ព្រមទាំងគាំទ្រដោយប្រាក់បញ្ញើអតិថិជន ១២០,៨ ទ្រីលានរៀល (២៩,៥ ប៊ីលានដុល្លារអាមេរិក) ដើមទុន ២៥,១ ទ្រីលានរៀល (៥,៨ ប៊ីលានដុល្លារអាមេរិក) និងមូលនិធិកម្ចី ១៧ ទ្រីលានរៀល (៤,១ ប៊ីលានដុល្លារអាមេរិក)។ ជាមួយគ្នានេះ បណ្ដាញប្រតិបត្តិការនៅតាមរាជធានី-ខេត្តរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបន្តកើនឡើង និងរួមចំណែកជំរុញបរិយាបន្នហិរញ្ញវត្ថុ។ ទីស្នាក់ការរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានកើនដល់ ២.៩៥០ សាខា ម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) ដល់ ២.៥២០ ម៉ាស៊ីន និងបានផ្ដល់សេវាប្រាក់បញ្ញើ ៧.៥៨៧.០៩៨ គណនី និងសេវាឥណទាន ៣.០៦៦.៨៤០ គណនី។ លើសពីនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានធ្វើពិពិធកម្មសេវាហិរញ្ញវត្ថុរបស់ខ្លួនឱ្យកាន់តែសកម្ម ដើម្បីសម្រួលដល់អតិថិជនជាមួយនឹងការប្រើប្រាស់ប័ណ្ណជំនួសសាច់ប្រាក់ ការផ្ដល់សេវាផ្ទេរប្រាក់ និងការទូទាត់សងប្រាក់អេឡិចត្រូនិក។

**ក្រាហ្វ ២២៖ ចំនួនប្រាក់បញ្ញើ និងឥណទានរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**
(ឆ្នាំ២០១២ -២០១៩)




**ក្រាហ្វ ២៣៖ ចំនួនគណនីប្រាក់បញ្ញើ និងគណនីឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ**
(ឆ្នាំ២០១២ -២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ២- វិស័យធនាគារ

គ្រឹះស្ថានធនាគារបានបន្តរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយទ្រព្យសកម្មសរុបរបស់គ្រឹះស្ថានធនាគារបានកើនឡើង ២២,៨% ដល់ ១៧១ ទ្រីលានរៀល (៤១,៨ ប៊ីលានដុល្លារអាមេរិក) ដែលគាំទ្រដោយប្រាក់បញ្ញើអតិថិជន ១០៤ ទ្រីលានរៀល (២៥,៥ ប៊ីលានដុល្លារអាមេរិក) ដើមទុន ២០,៤ ទ្រីលានរៀល (៥ ប៊ីលានដុល្លារអាមេរិក) និងមូលនិធិកម្ចី ៤,៩ ទ្រីលានរៀល (១,២ ប៊ីលានដុល្លារអាមេរិក)។ ឥណទានដែលជាប្រភពទុនយ៉ាងសំខាន់ក្នុងការគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច បានកើនឡើង ២៣,៨% ដល់ ១០០,៥ ទ្រីលានរៀល (២៤,៥ ប៊ីលានដុល្លារអាមេរិក) និងបានផ្ដល់ទៅវិស័យសេដ្ឋកិច្ចសំខាន់ៗរួមមាន ការជួញដូររាយ ១៦% ការជួញដូរដុំ ១១% ការឱ្យខ្ចីទិញផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ១០% សំណង់ ១០% កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៩% តម្រូវការផ្ទាល់ខ្លួន ៨% ការជួញដូរអចលនទ្រព្យ ៧% សេវាកម្មមិនមែនហិរញ្ញវត្ថុផ្សេងៗទៀត ៧% កម្មន្តសាលកម្ម ៥% សណ្ឋាគារនិងភោជនីយដ្ឋាន ៥% និងវិស័យផ្សេងៗ ១២%។

ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារភាគច្រើនបាននិងកំពុងអភិវឌ្ឍនិងពង្រីកបណ្តាញសាខា ធ្វើពិពិធកម្មផលិតផលនិងសេវាហិរញ្ញវត្ថុ និងអភិវឌ្ឍសេវាហិរញ្ញវត្ថុឌីជីថល ដោយបានផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការប្រើប្រាស់សេវាធនាគារតាមរយៈប្រព័ន្ធអ៊ីនធើណែតនិងទូរស័ព្ទចល័តជាដើម។

**ក្រាហ្វ ២៤ ៖ ឥណទានតាមវិស័យរបស់គ្រឹះស្ថានធនាគារ**
(ឆ្នាំ២០១៩)




**ក្រាហ្វ ២៥ ៖ អត្រាការប្រាក់របស់គ្រឹះស្ថានធនាគារ**
(គិតជាភាគរយ, ឆ្នាំ២០១៤ - តុលា ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើជារៀលនិងជាដុល្លារអាមេរិកមានអត្រាការប្រាក់ ៦,១៩% និង ៤,៩៥% រៀងគ្នា ធៀបនឹងឆ្នាំមុន ៦,២១% និង ៤,៨៤% ដែលមានកម្រិតថេរក្នុងរយៈពេល២ឆ្នាំចុងក្រោយ បន្ទាប់ពីបានថយចុះពីអត្រាប្រមាណ ៧,៤% និង ៥,២% រៀងគ្នា នៅឆ្នាំ២០១៦។ ដោយឡែក អត្រាការប្រាក់ឥណទានជារៀល និងជាដុល្លារអាមេរិកមាននិន្នាការថយចុះក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយបានថយចុះបន្តិចពី ១៣,៧% និង ១០,៥% រៀងគ្នានៅឆ្នាំមុន មក ១១,៩% និង ៨,១%។ ការថយចុះជារួមនៃអត្រាការប្រាក់ជាដុល្លារអាមេរិក អាចដោយសារកត្តាកំណើនលំហូរទុនវិនិយោគបន្ថែមពីខាងក្រៅ និងបរិយាកាសប្រកួតប្រជែងក្នុងវិស័យធនាគារ ខណៈដែលការថយចុះនៃអត្រាការប្រាក់ជារៀលដោយសារការអនុវត្តគោលនយោបាយលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលជាពិសេសក្នុងប្រព័ន្ធធនាគារ។

## ៣- វិស័យមីក្រូហិរញ្ញវត្ថុ

វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា បានបន្តរីកចម្រើនគួរឱ្យកត់សម្គាល់ប្រកបដោយនិរន្តរភាព និងបរិយាបន្ន។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកេណ្ឌប្រមូលប្រាក់បញ្ញើសរុប ១៦,៤ ទ្រីលានរៀល (៣,៩ ប៊ីលានដុល្លារអាមេរិក) និងបានផ្តល់ឥណទាន ៣០,១ ទ្រីលានរៀល (៧,២ ប៊ីលានដុល្លារអាមេរិក) ទៅកាន់វិស័យសេដ្ឋកិច្ចសំខាន់ៗ រួមមាន ក្រុមគ្រួសារ ៣៤% កសិកម្ម ២០% ពាណិជ្ជកម្ម ១៨% សេវាកម្ម ១៤% ដឹកជញ្ជូន ៦% សំណង់ ៣% និងផ្សេងៗ ៥%។

ក្រាហ្វ ២៦ ៖ ឥណទានតាមវិស័យរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
(ឆ្នាំ២០១៩)




ក្រាហ្វ ២៧ ៖ អត្រាការប្រាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
(គិតជាភាគរយ, ឆមាស២ ឆ្នាំ២០១៤ - ឆ្នាំ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ជាមួយគ្នានេះ គ្រឹះស្ថានឥណទានជនបទដែលទទួលបានវិញ្ញាបនបត្រពីធនាគារជាតិនៃកម្ពុជា មាន ២៤៨ និងមានសមតុល្យឥណទានសរុប ៤០១.៥០ ប៊ីលានរៀល (០,១ ប៊ីលានដុល្លារអាមេរិក) ដោយបានផ្តល់ដល់អតិថិជន ១៩៤.០១៥ នាក់។

អត្រាការប្រាក់បញ្ញើជារៀលនិងដុល្លារអាមេរិកមានកម្រិតប្រហាក់ប្រហែលនឹងឆ្នាំមុន ដោយមានកម្រិតប្រែប្រួលតិច ក្នុងអត្រាជាមធ្យម ៨% និង ៧,៨% រៀងគ្នា។ ទន្ទឹមនេះ អត្រាការប្រាក់ឥណទានជារៀលនិងដុល្លារអាមេរិកមានការថយចុះជាលំដាប់ពី ៣៤,៥% និង ២៩,៦% រៀងគ្នា ក្នុងឆ្នាំ២០១៦ មកត្រឹម ២២,៩% និង ២០% រៀងគ្នា ក្នុងឆ្នាំ២០១៧ និង មកត្រឹម ១៥% និង ១៦% រៀងគ្នា ក្នុងឆ្នាំ២០១៩ បន្ទាប់ពីការដាក់ចេញនូវប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទាន ១៨% ដែលការណ៍នេះបានផ្តល់ផលវិជ្ជមានច្រើនដល់អតិថិជនមីក្រូហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ការកំណត់ពិដានអត្រាការប្រាក់ឥណទាននេះ បានជំរុញឱ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុយកចិត្តទុកដាក់ក្នុងការពង្រឹងប្រសិទ្ធភាពប្រតិបត្តិការបន្ថែម និងការកាត់បន្ថយចំណាយតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុជាដើម។

## ៤- ភតិសន្យាហិរញ្ញវត្ថុ

ភតិសន្យាហិរញ្ញវត្ថុ គឺជាសេវាមួយក្នុងចំណោមសេវាហិរញ្ញវត្ថុផ្សេងទៀត ដែលអាចជួយសហគ្រាសធុនតូចនិងមធ្យម (SMEs) ជាពិសេសសហគ្រាសធុនតូចនិងមធ្យមដែលទើបនឹងចាប់ផ្តើមប្រកបអាជីវកម្ម ក្នុងការទទួលបានហិរញ្ញប្បទានរយៈពេលខ្លីនិងរយៈពេលវែង និងការគ្រប់គ្រងលំហូរសាច់ប្រាក់ឱ្យមានប្រសិទ្ធភាពជាងមុន ដោយមិនចាំបាច់ធ្វើការទូទាត់ដុលភ្លាមៗក្នុងការទិញឧបករណ៍និងមធ្យោបាយផលិតកម្ម ប៉ុន្តែអាចធ្វើការទូទាត់ក្នុងរយៈពេលណាមួយសមស្រប។ ជាក់ស្តែង សេវាភតិសន្យាហិរញ្ញវត្ថុបានចូលរួមចំណែកយ៉ាងសកម្មក្នុងការជួយដល់វិស័យកសិកម្ម តាមរយៈការជួលគ្រឿងចក្រកសិកម្មដូចជា ម៉ាស៊ីនច្រូតស្រូវ គោយន្ត និងវត្ថុធាតុដើមកសិកម្ម ជាដើម ដោយពុំចាំបាច់មានទ្រព្យធានា។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យភតិសន្យាហិរញ្ញវត្ថុមានការីកចម្រើនគួរឱ្យកត់សម្គាល់ ដោយចំនួនក្រុមហ៊ុនបានកើនពី ៩ ក្រុមហ៊ុន ក្នុងឆ្នាំ២០១៥ ដល់ ១៥ ក្រុមហ៊ុន ក្នុងឆ្នាំ២០១៩ ហើយទំហំទ្រព្យសកម្មសរុបបានកើនឡើងប្រមាណបីដងពី ៤១០,៣៥ ប៊ីលានរៀល (១០១,៣

លានដុល្លារអាមេរិក) ដល់ ១,៣២ ទ្រីលានរៀល (៣២៦ លានដុល្លារអាមេរិក)។ ឥណទានភតិសន្យាសរុបបានកើនឡើង ៥៩,៥% ដល់ ១,២ ទ្រីលានរៀល (២៨១ លានដុល្លារអាមេរិក) ដោយមានអតិថិជន ១០២.៥២៤ នាក់ ដែលបានបែងចែកទៅកាន់វិស័យសំខាន់ៗ រួមមាន ការប្រើប្រាស់ ៣០% សេវាកម្ម ១៨% ការដឹកជញ្ជូន ១២% សំណង់ ៨% កសិកម្ម ៧% អាជីវកម្មនិងពាណិជ្ជកម្ម ៧% និងផ្សេងៗ ១៨%។ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុមានដើមទុនចុះបញ្ជីសរុប ០,៣១ ទ្រីលានរៀល (៧៦,៥ លានដុល្លារអាមេរិក) អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម ២,៨% អនុបាតប្រាក់ចំណេញធៀបនឹងដើមទុន ៦,៣% អនុបាតសាធនភាព ៣៥% និងភតិសន្យាហិរញ្ញវត្ថុមិនដំណើរការ ៣,៧%។

### ៥- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

ដើម្បីធានាបាននូវប្រសិទ្ធភាព និងសុវត្ថិភាពនៃប្រព័ន្ធធនាគារទាំងមូល ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ក្នុងការតាមដានយ៉ាងតឹងរ៉ឹងលើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធំៗ ដែលមានហានិភ័យខ្ពស់ ដោយពិនិត្យលើភាពងាយរងផលប៉ះពាល់ពីវិស័យអចលនទ្រព្យ និងការអនុវត្តច្បាប់និងបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

ជារួម ស្ថានភាពហិរញ្ញវត្ថុ និងការអនុវត្តច្បាប់និងបទប្បញ្ញត្តិរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុស្ថិតនៅក្នុងស្ថានភាពល្អ លើកលែងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនតូចតម្រូវឱ្យពង្រឹងបន្ថែមលើការអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងនិងអភិបាលកិច្ច ឱ្យស្របតាមការរីកចម្រើននៃទំហំនិងវិសាលភាពនៃប្រតិបត្តិការរបស់ខ្លួន។ ដើម្បីកែតម្រូវចំណុចខ្វះខាតរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានចេញអនុសាសន៍ឱ្យគ្រឹះស្ថានអនុវត្ត និងបន្តធ្វើការត្រួតពិនិត្យ និងតាមដានជាប្រចាំចំពោះរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តតាមអនុសាសន៍ដែលបានដាក់ចេញ។ បន្ថែមពីនេះ ធនាគារជាតិនៃកម្ពុជា បានចាត់វិធានការតឹងរ៉ឹងចំពោះគ្រឹះស្ថានមួយចំនួនដែលមិនអនុវត្តតាមអនុសាសន៍បានពេញលេញ ស្របតាមបទប្បញ្ញត្តិជាធរមាន។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាកំពុងបោះជំហានក្នុងការអនុវត្តការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគតឱ្យបានលទ្ធផលល្អ ដោយបាននិងកំពុងធ្វើកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោម៖

i/- ពិភាក្សានិងកែសម្រួលផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តការត្រួតពិនិត្យផ្អែកលើហានិភ័យ

ii/-បង្កើតក្រុមការងារឯកទេសកម្មចំនួន ៦ ក្រុម ដើម្បីគាំទ្រវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យឱ្យមានប្រសិទ្ធភាព ដែលក្រុមទាំងនោះរួមមានក្រុមការងារឯកទេសហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការនិងព័ត៌មានវិទ្យា ហានិភ័យសន្ទនីយភាព ហានិភ័យដើមទុន និងគណនេយ្យ និង

iii/-ពង្រឹងសមត្ថភាពនិងជំនាញរបស់មន្ត្រី អំពីការត្រួតពិនិត្យផ្អែកលើហានិភ័យ។

### ៦- ការវិភាគស្ថិរភាពហិរញ្ញវត្ថុ

ការងារតាមដាននិងវាយតម្លៃស្ថានភាពស្ថិរភាពហិរញ្ញវត្ថុត្រូវបានយកចិត្តទុកដាក់ជាប្រចាំ។ កាលពីខែមេសា ឆ្នាំ២០១៩ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយសៀវភៅស្តីពី ស្ថានភាពស្ថិរភាព

ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨[១៦] ជាលើកដំបូង។

នៅឆ្នាំ២០១៩នេះ ស្ថិរភាពហិរញ្ញវត្ថុកម្ពុជាបន្តមានស្ថានភាពល្អប្រសើរ គួបផ្សំនឹងកំណើនរឹងមាំនៃសកម្មភាពសេដ្ឋកិច្ចកម្ពុជា ដែលគាំទ្រដោយកំណើនតម្រូវការក្នុងស្រុកនិងការនាំចេញ ទោះបីជាកំណើនសេដ្ឋកិច្ចពិភពលោកនិងទំហំពាណិជ្ជកម្មអន្តរជាតិបានថមថយល្បឿនបន្តិចក៏ដោយ។ នៅក្នុងវិស័យធនាគារ សូចនាករដែលបង្ហាញពីស្ថិរភាពរឹងមាំនៃវិស័យនេះ រួមមាន i/-ភាពគ្រប់គ្រាន់នៃដើមទុន ii/-ភាពគ្រប់គ្រាន់នៃសន្ទនីយភាព iii/-កម្រិតទាបនៃឥណទានមិនដំណើរការ និង iv/-ភាពប្រសើរឡើងនៃប្រាក់ចំណេញ។ ជាក់ស្តែង អនុបាតសាធនភាពនិងអនុបាតក្របខ័ណ្ឌសន្ទនីយភាពជាមធ្យម សម្រាប់គ្រឹះស្ថានធនាគារមាន ២៤,៥% និង ១៧០,៨% និងសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមាន ១៩,២% និង ១៨៣,៥% រៀងគ្នា (ធៀបនឹងកម្រិតកំណត់ ១៥% និង ៩០%)។ អនុបាតឥណទានមិនដំណើរការបន្តមានកម្រិតទាបប្រមាណ ២,២% សម្រាប់គ្រឹះស្ថានធនាគារ និង ១,១% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ លើសពីនេះ អនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម (ROA) ប្រមាណ ២% សម្រាប់គ្រឹះស្ថានធនាគារ និង ២,៨% សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

**ក្រាហ្វ ២៨ ៖ កំណើនឥណទាន និងកំណើនសេដ្ឋកិច្ច**

(គិតជាភាគរយ, ឆ្នាំ២០១០-២០១៩)




ជាមួយគ្នានេះ ហានិភ័យមួយចំនួនដែលអាចប៉ះពាល់ដល់ស្ថិរភាពហិរញ្ញវត្ថុ រួមមាន កំណើនឥណទានបន្តមានកម្រិតខ្ពស់ ជាពិសេសកំណើនឥណទានទៅកាន់វិស័យសំណង់និងអចលនទ្រព្យ និងការផ្តល់ឥណទានដោយផ្ទាល់របស់ក្រុមហ៊ុនអភិវឌ្ឍន៍អចលនទ្រព្យមួយចំនួនដែលមិនមានការត្រួតពិនិត្យត្រឹមត្រូវ។ ចំពោះមូលនិធិកម្ចីពីខាងក្រៅ ហានិភ័យនៅមានកម្រិតទាបនិងអាចគ្រប់គ្រងបាន ដោយទំហំមូលនិធិកម្ចីមានប្រមាណ ១៥% នៃប្រភពមូលនិធិសរុបរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ហើយក្នុងនោះ ៧៤% នៃមូលនិធិកម្ចីសរុបមានឥណប្រតិទានរយៈពេលលើសពី ១ឆ្នាំ និងភាគច្រើនទទួលបានពីធនាគារមេ ភាគទុនិក និងដៃគូអភិវឌ្ឍន៍។

ដើម្បីកាត់បន្ថយហានិភ័យនានា និងពង្រឹងស្ថិរភាពហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានតាមដានហានិភ័យយ៉ាងយកចិត្តទុកដាក់ និងពង្រឹងការអនុវត្តវិធានការមីក្រូនិងម៉ាក្រូប្រុងប្រយ័ត្ន ដែលមានលក្ខណៈបុរេសកម្ម ជាពិសេសការបង្កើនទ្រនាប់ដើមទុន ក្របខ័ណ្ឌគ្រប់គ្រងសន្ទនីយភាព និងការពង្រឹងការវាយតម្លៃនិងចំណាត់ថ្នាក់គុណភាពឥណទាន ជាដើម។ ទន្ទឹមនេះ វិធានការមួយចំនួនផ្សេងទៀតកំពុងត្រូវបានសិក្សានិងត្រៀមអនុវត្តនាពេលខាងមុខ។

[១៦] សៀវភៅនេះបានបង្ហាញពីការវិភាគទៅលើស្ថានភាពនិងហានិភ័យនានានៅក្នុងសេដ្ឋកិច្ច វិស័យធនាគារ ភាពប្រទាក់ក្រឡាវវាងវិស័យធនាគារនិងសេដ្ឋកិច្ច និងហានិភ័យជាប្រព័ន្ធផ្សេងៗ ព្រមទាំងសិក្សាអំពីលទ្ធភាពក្នុងការដាក់ចេញវិធានការម៉ាក្រូប្រុងប្រយ័ត្ន។

**ក្រាហ្វ ២៩ ៖ អនុបាតឥណទានមិនដំណើរការគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
(ឆ្នាំ២០១២ - ២០១៩)




**ក្រាហ្វ ៣០៖ ប្រភពទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ**
(ឆ្នាំ២០១៣ - ២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣១ ៖ សន្ទនីយភាពនិងសាធនភាពរបស់គ្រឹះស្ថានធនាគារ**
(ឆ្នាំ២០១២ - ២០១៩)




**ក្រាហ្វ ៣២ ៖ សន្ទនីយភាពនិងសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**
(ឆ្នាំ២០១២ - ២០១៩)




ប្រភព ៖ ធនាគារជាតិនៃកម្ពុជា

## ៧- ការត្រួតពិនិត្យការិយាល័យឥណទាន

ក្រុមហ៊ុន ក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូ អិលធីឌី មានទ្រព្យសកម្មសរុបប្រមាណ ៥៩,៦ ប៊ីលានរៀល (១៤,៦ លានដុល្លារអាមេរិក) និងមានគ្រឹះស្ថានជាសមាជិកក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានចំនួន ១៦៧ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានសហគ្រាស ត្រូវបានដាក់ឱ្យដំណើរការពេញលេញ ហើយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបញ្ចូលទិន្នន័យឥណទានសហគ្រាសទាំងអស់ទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

## ៨- ការខារបរិយាបន្នហិរញ្ញវត្ថុ និងការអប់រំផ្នែកហិរញ្ញវត្ថុ

យុទ្ធសាស្ត្រជាតិស្ដីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥ លើកឡើងនូវគោលនយោបាយដែលចង្អុលបង្ហាញពីគោលដៅក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ ដោយបង្កើនលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុផ្លូវការដែលមានគុណភាព កាត់បន្ថយអត្រាស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុឱ្យបានពាក់កណ្ដាលពី ២៧% មក ១៣% និងពង្រីកការប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការពី ៥៩% ទៅ ៧០% ត្រឹមឆ្នាំ២០២៥ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពគ្រួសារ និងគាំទ្រកំណើនសេដ្ឋកិច្ច តាមរយៈសកម្មភាពអាទិភាព ដូចជា៖ i/- លើកទឹកចិត្តឱ្យមានការសន្សំនៅតាមគ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការ ii/- ជំរុញនវានុវត្តន៍សេវាឥណទាន សម្រាប់សហគ្រាសធុនតូចនិងមធ្យម iii/- ពង្រីក

សមត្ថភាពប្រព័ន្ធទូទាត់ iv/- ពង្រីកការផ្តល់សេវាធានារ៉ាប់រងឱ្យបានទូលំទូលាយ v/- ពង្រឹងសមត្ថភាពនិយ័តករវិស័យហិរញ្ញវត្ថុ និង vi/- លើកកម្ពស់សិទ្ធិនិងបង្កើនកិច្ចការពារអតិថិជន ព្រមទាំងបង្កើនតម្លាភាពក្នុងវិស័យហិរញ្ញវត្ថុ។

ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាបានបន្តលើកកម្ពស់ការអប់រំផ្នែកហិរញ្ញវត្ថុជាប្រចាំតាមរយៈយុទ្ធនាការនានា ដូចជាការរៀបចំសិក្ខាសាលាស្តីពីវិស័យមីក្រូហិរញ្ញវត្ថុនៅតាមបណ្តាខេត្ត ការផ្សព្វផ្សាយពីសៀវភៅអប់រំផ្នែកហិរញ្ញវត្ថុទៅដល់ប្រជាជននៅតាមមូលដ្ឋាន ការអប់រំពីតួនាទីនិងសារប្រយោជន៍របស់សេវាហិរញ្ញវត្ថុផ្លូវការតាមខិតប័ណ្ណនិងបណ្តាញសង្គមនានា និងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុតាមទូរស័ព្ទចល័ត ជាដើម។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះដឹងទូទៅ ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ ព្រមទាំងបានសហការជាមួយក្រសួងកិច្ចការនារី ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី និងស្ត្រីក្នុងសហគ្រិនភាព។

## ប្រអប់ ៥ ៖ វឌ្ឍនភាពការងារផ្សេងៗ

### ក- ការងាររៀបចំបទប្បញ្ញត្តិ

ធនាគារជាតិនៃកម្ពុជាបានរៀបចំសេចក្តីពន្យល់បន្ថែមលើប្រកាសស្តីពីការកំណត់ទ្រនាប់ដើមទុនរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រកាសស្តីពីអនុបាតគ្របខណ្ឌសន្ទនីយភាព, រៀបចំសិក្ខាសាលាជាបន្តបន្ទាប់ដើម្បីពន្យល់បកស្រាយបន្ថែមទៅដល់សមាគមគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ព្រមទាំងមានផែនការអនុម័តប្រកាសទាក់ទងសាធនភាព ការឆ្លើយតបផ្នែកត្រួតពិនិត្យចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុខ្សោយ និងការកំណត់អត្រាឥណទានធៀបនឹងទ្រព្យបញ្ចាំ (Loan-to-Value Ratio) នៅឆ្នាំ២០២០។

### ខ- ការងារបរិយាបន្នហិរញ្ញវត្ថុ និងការអប់រំផ្នែកហិរញ្ញវត្ថុ

ធនាគារជាតិនៃកម្ពុជាបានធ្វើជាស្ថាប័នដឹកនាំការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ "យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុឆ្នាំ២០១៩-២០២៥" ទទួលបានឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ និងចុះហត្ថលេខាដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩។

លើសពីនេះ ធនាគារជាតិនៃកម្ពុជាបានរៀបចំកម្មវិធីផ្សព្វផ្សាយចំណេះដឹងផ្នែកហិរញ្ញវត្ថុជូនសាធារណជន ក្នុងគោលបំណងប្រមូល ផ្សព្វផ្សាយ និងពិនិត្យឡើងវិញនូវសមិទ្ធផលនៃចំណេះដឹងផ្នែកហិរញ្ញវត្ថុដែលភាគីពាក់ព័ន្ធនៅក្នុងវិស័យបានរៀបចំនិងអនុវត្ត។ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីចំណេះដឹងទូទៅ និងបានចុះអនុស្សរណៈយោគយល់ជាមួយក្រសួងកិច្ចការនារី ស្តីពីការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុសម្រាប់ស្ត្រី និងស្ត្រីក្នុងសហគ្រិនភាព។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជា បានសហការជាមួយក្រសួងកិច្ចការនារី និងក្រុមហ៊ុន VISA រៀបចំកម្មវិធីផ្សព្វផ្សាយស្តីពី "ចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅកម្ពុជា" ដើម្បីបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅដល់យុវតី សហគ្រិនស្ត្រីឬក្រុមស្ត្រីនៅតាមមូលដ្ឋាន និងបង្កើន

សហគ្រិនភាពសម្រាប់យុវតីនៅថ្នាក់បឋមសិក្សានិងមធ្យមសិក្សា។

ធនាគារជាតិនៃកម្ពុជាបានបន្តកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីរៀបចំការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុដំណាក់កាលទី២ ក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងឆ្នាំ២០២០។ ការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុដំណាក់កាលទី២ នឹងត្រូវបញ្ចូលទៅក្នុងកម្មវិធីសិក្សាលម្អិតលើមុខវិជ្ជា៖ គេហសេដ្ឋកិច្ច (Home Economics) បំណិនជីវិត (Life Skill) សិក្សាសង្គម (Social Study) និងគណិតវិទ្យា ហើយក្រុមការងារនឹងរៀបចំចងក្រងជាសៀវភៅសិក្សាសម្រាប់សិស្សានុសិស្សនៅឆ្នាំសិក្សាថ្មីខាងមុខ ស្របពេលដែលក្រសួងអប់រំ យុវជន និងកីឡាត្រូវធ្វើបច្ចុប្បន្នកម្មលើសៀវភៅសិក្សាតែម្តង។

ធនាគារជាតិនៃកម្ពុជាក៏បានបន្តចុះផ្សព្វផ្សាយសៀវភៅអប់រំផ្នែកហិរញ្ញវត្ថុ "តោះ!និយាយពីលុយ" នៅតាមមូលដ្ឋានគោលដៅមួយចំនួនដូចជា ខេត្តព្រៃវែង ពោធិ៍សាត់ តាកែវ កំពង់ចាម និងកំពង់ធំ ដោយបានចែកចាយសៀវភៅអប់រំផ្នែកហិរញ្ញវត្ថុ "តោះ! និយាយពីលុយ"សរុបចំនួន ២៥.០២៦ ក្បាល ក្នុងគោលបំណងផ្សព្វផ្សាយ និងលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្សថ្នាក់បឋមសិក្សានៅតាមមូលដ្ឋាន។ តាមរយៈកិច្ចសហការគ្នាជាមួយអង្គការ Good Return ក្នុងយុទ្ធនាការ "តោះ!និយាយពីលុយ" ធនាគារជាតិនៃកម្ពុជាគ្រោងធ្វើការបណ្តុះបណ្តាលកម្មការិនីតាមរោងចក្រនានា ដើម្បីអំពាវនាវដល់អ្នកប្រើប្រាស់ផលិតផលហិរញ្ញវត្ថុឱ្យយល់ដឹងពីសារៈសំខាន់នៃការគិតពិចារណានិងថ្លឹងថ្លែងជម្រើសផលិតផលហិរញ្ញវត្ថុ សិទ្ធិនិងការទទួលខុសត្រូវ នៅពេលធ្វើការសម្រេចចិត្ត។

ធនាគារជាតិនៃកម្ពុជា សហការជាមួយវិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី (ADBI) និងអង្គការដើម្បីអភិវឌ្ឍនិងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) បានរៀបចំសិក្ខាសាលាស្តីពី "តួនាទីនៃការអប់រំហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជនក្នុងការគាំទ្រដល់បរិយាបន្នហិរញ្ញវត្ថុ" ក្នុងគោលបំណងផ្សព្វផ្សាយពីយុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុ និងកម្រិតចំណេះដឹងផ្នែកហិរញ្ញវត្ថុនៅក្នុងតំបន់។

**គ- ការងារផ្សព្វផ្សាយស្តីពីវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា**

ធនាគារជាតិនៃកម្ពុជាបន្តរៀបចំសិក្ខាសាលាស្តីពី វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដើម្បីផ្សព្វផ្សាយជូនអាជ្ញាធរដែនដី ប្រជាពលរដ្ឋ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានឥណទានជនបទ ឱ្យបានយល់ដឹងកាន់តែច្បាស់អំពី i/-សារៈសំខាន់និងផលប្រយោជន៍នៃវិស័យមីក្រូហិរញ្ញវត្ថុ ii/-តួនាទីភារកិច្ចនៃធនាគារជាតិនៃកម្ពុជា iii/-កាតព្វកិច្ច និងការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន និង iv/-ការយល់ដឹងពីការប្រើប្រាស់សេវាហិរញ្ញវត្ថុ សំដៅបញ្ជ្រាបចំណេះដឹងពីវិស័យមីក្រូហិរញ្ញវត្ថុ និងបញ្ចៀសបំណុលលើសលប់របស់ប្រជាពលរដ្ឋ។ សិក្ខាសាលានេះបានធ្វើឡើងសរុបចំនួន ៧ លើក ក្នុងនោះមានថ្នាក់ខេត្តចំនួន ១ លើក និងថ្នាក់ស្រុកចំនួន ៦ លើក។ សមាសភាពដែលចូលរួមការផ្សព្វផ្សាយទាំងអស់មានចំនួន ៣.៨៨៥ នាក់ ដែលជាអាជ្ញាធរដែនដី ប្រធាន-អនុប្រធានភូមិ នាយក-នាយករង លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ។

**ឃ- យន្តការគ្រប់គ្រង និងដោះស្រាយបណ្តឹងអតិថិជន**

ក្នុងគោលបំណងផ្តល់ព័ត៌មាន ការពារសិទ្ធិ ការពារផលប្រយោជន៍របស់អតិថិជន ព្រមទាំងពង្រឹងជំនឿទុកចិត្តរបស់សាធារណជនលើប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានបន្តទទួល និងដោះស្រាយការតវ៉ា និង/ឬបណ្តឹងតាមរយៈប្រព័ន្ធទូរស័ព្ទ Hotline ទាំង ៥ ខ្សែ សម្រាប់ទីស្នាក់ការ

កណ្តាល និង ២១ ខ្សែ នៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត។ ក្រុមការងារ Hotline បានទទួលបណ្តឹងចំនួន ២៣៥ ករណី ដែលភាគច្រើនពាក់ព័ន្ធនឹងការបង់ផ្តាច់ឥណទានមុនកាលកំណត់ បញ្ហាស្នើសុំដកវត្ថុបញ្ចាំ ការគណនាការប្រាក់ ការខ្ជិចងការប្រាក់ក្រៅប្រព័ន្ធធនាគារ និងការបង់ពិន័យផ្សេងៗ។ល។

**ង- វឌ្ឍនភាពរបស់គម្រោងបង្កើតប្រព័ន្ធការពារប្រាក់បញ្ញើ**

ដើម្បីជំរុញការអភិវឌ្ឍប្រព័ន្ធការពារប្រាក់បញ្ញើនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១៦-២០២៥ និងអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានបង្កើតក្រុមការងារ សម្រាប់សិក្សារៀបចំសេចក្តីព្រាងគោលនយោបាយ និងក្របខ័ណ្ឌច្បាប់នៃប្រព័ន្ធការពារប្រាក់បញ្ញើ និងក្របខ័ណ្ឌដំណោះស្រាយ។

## V- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

### ១- ប្រព័ន្ធទូទាត់សងប្រាក់

#### ក- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់

ធនាគារជាតិនៃកម្ពុជាបានបន្តអភិវឌ្ឍប្រព័ន្ធទូទាត់តម្លៃរាយនិងតម្លៃធំ លើកកម្ពស់ការត្រួតពិនិត្យ និងរៀបចំបទប្បញ្ញត្តិគ្រប់គ្រងប្រព័ន្ធទូទាត់ ដើម្បីកាត់បន្ថយហានិភ័យជាប្រព័ន្ធ ការពារផលប្រយោជន៍អតិថិជន និងជំរុញការប្រើប្រាស់ការទូទាត់អេឡិចត្រូនិក សំដៅឆ្លើយតបទៅនឹងការរីកចម្រើននៃសេវា និងឧបករណ៍ទូទាត់ ព្រមទាំងធានានិរន្តរភាពនៃដំណើរការប្រព័ន្ធទូទាត់។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីជូនដំណឹងស្តីពី គោលការណ៍ណែនាំក្នុងការចូលរួមជាសមាជិកមិនផ្ទាល់ និងកិច្ចសហការរវាងសមាជិកផ្ទាល់និងមិនផ្ទាល់ក្នុងប្រព័ន្ធផាត់ទាត់ជាតិ ដើម្បីជំរុញឱ្យសមាជិកទាំងអស់ចូលរួមអនុវត្តឱ្យបានត្រឹមត្រូវនូវគោលនយោបាយថ្មីពាក់ព័ន្ធនឹងការកែសម្រួលសមាជិកភាពប្រព័ន្ធផាត់ទាត់ជាតិ។ បច្ចុប្បន្ននេះ ប្រព័ន្ធសេវាទូទាត់រហ័សក៏មានការចូលរួមពីគ្រឹះស្ថានសមាជិកថ្មីៗបន្ថែមទៀត។ ចំណែកឯ ប្រព័ន្ធខេមបូខានស៊ែស្វីចដែលកំពុងដាក់ឱ្យដំណើរការបឋម ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តអនុវត្តការធ្វើសន្ធានកម្មប្រព័ន្ធជាមួយគ្រឹះស្ថានសមាជិកដទៃទៀត ដូច្នេះគ្រឹះស្ថានសមាជិកចូលរួមក្នុងដំណើរការបឋមបានកើនដល់ ១៥ គ្រឹះស្ថាន។ កាលពីខែតុលាឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាសហការជាមួយគ្រឹះស្ថានសមាជិកចំនួន ៧ បានដាក់ឱ្យដំណើរការបឋមប្រព័ន្ធរីថៃលផេ (Retail Pay) ដែលត្រូវបានអភិវឌ្ឍក្រោមជំនួយឧបត្ថម្ភពីទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) ដើម្បីផ្តល់ជាជម្រើសបន្ថែមទៀតសម្រាប់អតិថិជនធ្វើប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់រាយនៅកម្ពុជា។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ ប្រព័ន្ធបាគងដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆែន (blockchain) ត្រូវបានដាក់ឱ្យដំណើរការសាកល្បង ដោយមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៩ ចូលរួម។ ប្រព័ន្ធបាគងគ្រោងនឹងដាក់ឱ្យដំណើរការជាផ្លូវការនៅដើមឆ្នាំ២០២០ និងមានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចូលរួមជាច្រើនបន្ថែមទៀត។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាសហការជាមួយសមាគមធនាគារនៅកម្ពុជានិងភាគីពាក់ព័ន្ធបាននិងកំពុងរៀបចំអភិវឌ្ឍស្តង់ដា QR Code អនុលោមតាមស្តង់ដា EMV ដើម្បីសម្រួលដល់ការទូទាត់ឆ្លងគ្នារវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងការអនុវត្តគម្រោង

ភ្ជាប់ការទូទាត់ជាមួយប្រទេសក្នុងតំបន់។ បច្ចុប្បន្ន ប្រជាជនប្រមាណ ៥លាននាក់កំពុងប្រើប្រាស់សេវាទូទាត់សងប្រាក់តាមអេឡិចត្រូនិក ដែលមាន ៧៧ លានប្រតិបត្តិការ និងទំហំទឹកប្រាក់ប្រមាណ ៩៤ ទ្រីលានរៀល។

**ខ- ការត្រួតពិនិត្យប្រព័ន្ធទូទាត់សងប្រាក់ និងសេវាទូទាត់សងប្រាក់**

ធនាគារជាតិនៃកម្ពុជាបន្តពិនិត្យនិងតាមដានប្រតិបត្តិការប្រព័ន្ធទូទាត់ដែលដំណើរការដោយសភាផាត់ទាត់ជាតិ ដើម្បីធានាថា ប្រព័ន្ធនេះដំណើរការដោយរលូន និងប្រកបដោយសុវត្ថិភាពខ្ពស់។ ជាលទ្ធផល ប្រព័ន្ធទូទាត់បានធ្វើប្រតិបត្តិការទូទាត់និងផាត់ទាត់ប្រកបដោយជោគជ័យ។

នៅឆ្នាំនេះ គ្រឹះស្ថានដែលទទួលបានអាជ្ញាប័ណ្ណផ្តល់សេវាទូទាត់សងប្រាក់មានចំនួន ២០ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចំនួន ៥ ទទួលបានការអនុញ្ញាតឱ្យផ្តល់សេវាទូទាត់សងប្រាក់។ ការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ត្រូវបានអនុវត្តតាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង។ ក្នុងការត្រួតពិនិត្យលើឯកសារ ធនាគារជាតិនៃកម្ពុជា តម្រូវឱ្យគ្រប់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ផ្ញើរបាយការណ៍ប្រតិបត្តិការនិងហិរញ្ញវត្ថុជារៀលរាល់ខែ រួមទាំងព័ត៌មានចាំបាច់មួយចំនួនទៀត ដើម្បីធ្វើការវាយតម្លៃលក្ខណៈមីក្រូលើគ្រឹះស្ថាននីមួយៗ ដោយផ្តោតលើបញ្ហាប្រឈម និងការវិវត្តន៍របស់គ្រឹះស្ថានទាំងនោះជារៀងរាល់ត្រីមាសម្តង។ ចំពោះការត្រួតពិនិត្យដល់ទីកន្លែង ធនាគារជាតិនៃកម្ពុជាបានធ្វើការត្រួតពិនិត្យគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ៧ ក្នុងចំណោមគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ទាំង២០ ដោយបានផ្តល់អនុសាសន៍ដល់គ្រឹះស្ថានទាំងនោះឱ្យគោរពតាមគោលការណ៍ប្រុងប្រយ័ត្ន និងបន្តយកចិត្តទុកដាក់លើការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការការពារផលប្រយោជន៍អតិថិជន និងទប់ស្កាត់ហានិភ័យបទល្មើសបច្ចេកវិទ្យា។

**២- ប្រតិបត្តិការប្រព័ន្ធទូទាត់សងប្រាក់**

**ក- ប្រព័ន្ធផាត់ទាត់ជាតិ**

ប្រព័ន្ធផាត់ទាត់ជាតិមានសមាជិកសរុប ៤៥ (សមាជិកផ្ទាល់ ៣៣ និងមិនផ្ទាល់ ១២) និងមានមណ្ឌលដោះដូរមូលប្បទានប័ត្រ ៦ ដែលធ្វើតែសកម្មភាពដោះដូរមូលប្បទានប័ត្ររូបវន្តតែប៉ុណ្ណោះ។ ប្រព័ន្ធផាត់ទាត់ជាតិបានដំណើរការទូទាត់លើឧបករណ៍ ២ ប្រភេទគឺ មូលប្បទានប័ត្រ និងបញ្ជាផ្ទេរឥណទាន៖

- **សេវាផាត់ទាត់មូលប្បទានប័ត្រ៖** ការផាត់ទាត់មូលប្បទានប័ត្រជារៀលមាន ១៣,៣ ទ្រីលានរៀល (៤១,៣ ពាន់សន្លឹក) បានកើនឡើង ៤១,៥% ហើយការផាត់ទាត់មូលប្បទានប័ត្រជាប្រាក់ដុល្លារអាមេរិកមាន ៤៧,៥ ប៊ីលានដុល្លារអាមេរិក (១,៣ លានសន្លឹក) បានកើនឡើង ១៤,៥%។

- **សេវាទូទាត់បញ្ជាផ្ទេរឥណទាន៖** ការទូទាត់បញ្ជាផ្ទេរឥណទានដែលជាឧបករណ៍ទូទាត់សងប្រាក់អេឡិចត្រូនិកបានកើនឡើងគួរឱ្យកត់សម្គាល់។ ប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាប្រាក់រៀលមាន ៤,២ ទ្រីលានរៀល (៥,៩ ពាន់ប្រតិបត្តិការ) បានកើនឡើង ៤៤,៨% ហើយប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាប្រាក់ដុល្លារអាមេរិកមាន ៧,៦ ប៊ីលានដុល្លារអាមេរិក (២៣១,៩ ពាន់ប្រតិបត្តិការ) បានកើនឡើង ២៦,៥%។

**ខ- ប្រព័ន្ធសេវាទូទាត់រហ័ស**

ប្រព័ន្ធសេវាទូទាត់រហ័សមានសមាជិកសរុប ៤៣ ដោយក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ៧។ ប្រព័ន្ធសេវាទូទាត់រហ័ស បានដំណើរការទូទាត់លើប្រតិបត្តិការបញ្ជាផ្ទេរឥណទានជាប្រាក់រៀលចំនួន ១៨៧,៧ ប៊ីលានរៀល (កើន ៥៩,៦%)។

**គ- សេវាផ្ទេរប្រាក់តាមប្រព័ន្ធធនាគារអនឡាញ** (OBS)[១៧]

ប្រតិបត្តិការតាមប្រព័ន្ធ OBS រវាងគណនីនៅស្នាក់ការកណ្ដាលមិនត្រូវបានគិតកម្រៃសេវា ប៉ុន្តែការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្ដាលទៅគណនីនៅសាខារាជធានី-ខេត្ត ត្រូវគិតកម្រៃសេវា ០,១% នៃចំនួនប្រាក់ផ្ទេរ ដែលកម្រៃអតិបរមាគឺ ៤លានរៀល និងអប្បបរមា ១២.០០០រៀល។ ចំពោះការផ្ទេរប្រាក់ដែលជាថវិការដ្ឋមិនត្រូវបានគិតកម្រៃសេវាទេ។ ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS មាន ២២.៦២៧ ប្រតិបត្តិការ ស្មើនឹង ១៥៤ ទ្រីលានរៀល (កើន ១០៣,៥%) ក្នុងនោះការផ្ទេរប្រាក់រវាងគណនីនៅស្នាក់ការកណ្ដាលមាន ២១.៧៣១ ប្រតិបត្តិការ ស្មើនឹង ១៤៩,៨ ទ្រីលានរៀល (កើន ១០៥,៧%) និងការផ្ទេរប្រាក់ពីគណនីនៅស្នាក់ការកណ្ដាលទៅសាខារាជធានី-ខេត្តមាន ៨៩៦ ប្រតិបត្តិការ ស្មើនឹង ៤,៣ ទ្រីលានរៀល (កើន ៤៨,៨%)។

**ឃ- សេវាគ្រប់គ្រងគណនី**

ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីសរុប ១.៧២០ គណនី (កើន ៧៦គណនី) ក្នុងនោះគណនីរបស់ស្ថាប័នរដ្ឋ ៨៨៩ (កើន ២៦គណនី), គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ៧៩៨ (កើន ៥០គណនី) និងអង្គភាពផ្សេងៗ ៣៣។

ធនាគារជាតិនៃកម្ពុជាបានបន្តគាំទ្រនិងសហការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលក្នុងដំណាក់កាលទី៣ (២០១៦-២០២០) ដែលជាដំណាក់កាល "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ជាពិសេសតាមរយៈការប្រើប្រាស់សេវាប្រព័ន្ធ OBS ដែលត្រូវធ្វើសន្ទានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។ ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាបានបើកគណនីប្រាក់រង្វាន់ និងសម្របសម្រួលការផ្ទេរថវិកា និងការផ្ទេរប្រាក់បៀវត្សរ៍ (២ដងក្នុង១ខែ) របស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធដែលបើកគណនីនៅធនាគារដៃគូដែលអនុវត្តថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**៣- ការគ្រប់គ្រងចរាចរណ៍ធនប័ត្រ**

**ក- សកម្មភាពបេឡាប្រតិបត្តិការ**

បើធៀបនឹងឆ្នាំមុន ការទទួល និងការបើកប្រាក់រៀលបានកើនឡើង ៦,៥% និង ២៩,៥% រៀងគ្នា ស្របពេលការបើកប្រាក់ដុល្លារអាមេរិកបានកើនឡើង ១៩,៣% ហើយការទទួលប្រាក់ដុល្លារអាមេរិកបានកើនឡើង ១,៤%។

[១៧] ការផ្ទេរប្រាក់តាមប្រព័ន្ធ OBS គឺជាប្រតិបត្តិការផ្ទេរប្រាក់ដែលអនុវត្តដោយសមាជិកប្រព័ន្ធ OBS ដើម្បីផ្ទេរប្រាក់ពីគណនីមួយទៅគណនីមួយទៀតដែលបើកនៅធនាគារជាតិនៃកម្ពុជា។

**ក្រាហ្វ ៣៣ ៖ ការទទួលនិងការបើកប្រាក់រៀល**

(គិតជាប៊ីលានរៀល ឆ្នាំ២០១៥-២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

**ក្រាហ្វ ៣៤ ៖ ការទទួលនិងការបើកប្រាក់ដុល្លារអាមេរិក**

(គិតជាលានដុល្លារអាមេរិក ឆ្នាំ២០១៥-២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

## ខ- ការងារគ្រប់គ្រងសាច់ប្រាក់

ធនាគារជាតិនៃកម្ពុជាបានជួយសម្រួលក្នុងការគ្រប់គ្រងសាច់ប្រាក់ តាមរយៈការប្រមូលក្រដាសប្រាក់ចាស់ ការពង្រឹងគុណភាពក្រដាសប្រាក់ និងប្តូរក្រដាសប្រាក់រៀលថ្មីជូនប្រជាជននិងអាជីវករ។ ស្របតាម "យុទ្ធនាការស្រលាញ់ប្រាក់រៀល" ធនាគារជាតិនៃកម្ពុជាបានបើកទូលាយក្នុងការប្តូរក្រដាសប្រាក់រៀលថ្មីជូនប្រជាជនក្នុងឱកាសបុណ្យប្រពៃណីជាតិធំៗដូចជា ពិធីបុណ្យចូលឆ្នាំខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ។ ក្នុងឱកាសខួបលើកទី ១៥ នៃការគ្រងព្រះបរមរាជសម្បត្តិរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាចេញផ្សាយនិងដាក់ឱ្យចរាចរធនប័ត្រអនុស្សាវរីយ៍ប្រភេទ ១៥.០០០រៀល កាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩។

ការផ្គត់ផ្គង់ប្រាក់រៀលឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តទាំង១៩ បានកើនឡើង ៣៤,៩% រីឯការផ្គត់ផ្គង់ប្រាក់ដុល្លារអាមេរិកឱ្យសាខាធនាគារជាតិនៃកម្ពុជាបានកើនឡើង ៩,៤% ខណៈដែលការដឹកជញ្ជូនប្រាក់ដុល្លារអាមេរិកមកស្នាក់ការកណ្តាលវិញបានកើនឡើង ៦១,៧%។

**ក្រាហ្វ ៣៥ ៖ ប្រាក់រៀលដឹកទៅ-មក សាខាធនាគារជាតិនៃកម្ពុជា**
(គិតជាប៊ីលានរៀល ឆ្នាំ២០១៥-២០១៩)




**ក្រាហ្វ ៣៦ ៖ ប្រាក់ដុល្លារអាមេរិកដឹកទៅ-មក សាខាធនាគារជាតិនៃកម្ពុជា**
(គិតជាលានដុល្លារអាមេរិក ឆ្នាំ២០១៥-២០១៩)




ប្រភព៖ ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាក៏បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដកហូតក្រដាសប្រាក់រៀលក្លែងក្លាយ (ប្រភេទថតចម្លង) ២.៣៧៦ សន្លឹក និងក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយ ១៤៧ សន្លឹក គឺថយចុះ ៥០% និង ៤,៥% រៀងគ្នា (ឆ្នាំលើឆ្នាំ)។ ក្នុងចំណោមក្រដាសប្រាក់ដែលបានដកហូត ប្រភេទក្រដាសដែលក្លែងបន្លំច្រើនជាងគេមាន ១០.០០០ រៀល និង ១០០ ដុល្លារអាមេរិក។ លើសពីនេះ ដើម្បីបង្កើនការយល់ដឹងពីក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយស៊េរីថ្មី ធនាគារជាតិនៃកម្ពុជាសហការជាមួយធនាគារដៃគូបានរៀបចំសិក្ខាសាលាស្តីពីការពិនិត្យ និងសម្គាល់រូបិយប័ណ្ណក្លែងក្លាយនៅស្នាក់ការកណ្តាល និងសាខាធនាគារជាតិនៃកម្ពុជាខេត្តសៀមរាប។

## VI- **អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា** (ស.ហ.ក)

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) មានមុខងារនិងភារកិច្ចចម្បងក្នុងការទទួលរបាយការណ៍ប្រតិបត្តិការសង្ស័យ ប្រតិបត្តិការសាច់ប្រាក់ និងព័ត៌មានផ្សេងៗទៀត ដើម្បីវិភាគ វាយតម្លៃ និងបញ្ជូនរបាយការណ៍វិភាគ ទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការស៊ើបអង្កេត និងមានមុខងារស្នូលមួយទៀត គឺធានាថាបុគ្គលរាយការណ៍ត្រូវអនុវត្តតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន តាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែង។ ទន្ទឹមនេះ នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ស.ហ.ក បាននិងកំពុងដឹកនាំ សម្របសម្រួល និងសហការអនុវត្តការងារនានា ដើម្បីបំពេញការខ្វះចន្លោះនៃប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហានិភ័យថ្នាក់ជាតិឆ្នាំ២០១៦ របាយការណ៍វាយតម្លៃអញ្ញមញ្ញឆ្នាំ២០១៧ និងយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣។

### ១- ការរាយការណ៍ប្រតិបត្តិការរបស់បុគ្គលរាយការណ៍

ស.ហ.ក បានបន្តតាមដានជាប្រចាំនូវការរាយការណ៍ប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការសង្ស័យពីបុគ្គលរាយការណ៍ ស្របតាមសារតាហានិភ័យពាក់ព័ន្ធនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅកម្ពុជា។

ក្នុងឆ្នាំ២០១៩នេះ ស.ហ.ក បានទទួលរបាយការណ៍បន្ថែមទៀតពីក្រុមហ៊ុនអចលនទ្រព្យ កាស៊ីណូ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ផងដែរ។ ស.ហ.ក បានកត់សម្គាល់ឃើញថាបុគ្គលរាយការណ៍មានការជ្រួតជ្រាបពីកាតព្វកិច្ចរបស់ខ្លួន និងបានប្រតិបត្តិតាមយ៉ាងខ្ជាប់ខ្ជួនក្នុងការរាយការណ៍ជាទៀងទាត់ ស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

### ២- ការពង្រឹងការអនុវត្តកាតព្វកិច្ចបុគ្គលរាយការណ៍ និងបង្កើនការយល់ដឹង

ស.ហ.ក បានចុះត្រួតពិនិត្យដល់ទីកន្លែងលើធនាគារ ១៣ ក្រុមហ៊ុនកាស៊ីណូ ១២ និងក្រុមហ៊ុនអចលនទ្រព្យ ៥ ហើយបានផ្តល់ជាអនុសាសន៍ ដើម្បីពង្រឹងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៅតាមស្ថាប័នទាំងនោះ។ បច្ចុប្បន្ន ស.ហ.ក កំពុងប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យជាទម្រង់អេឡិចត្រូនិក ដើម្បីវាយតម្លៃពីកម្រិតហានិភ័យរបស់វិស័យធនាគារ។ ក្រៅពីនេះ ស.ហ.ក បានផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិដល់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់និងអ្នកដំណើរការតតីយភាគី ៨លើក និងសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការផ្សព្វផ្សាយ ៥លើក ជូនដល់ i/-ក្រុមហ៊ុនធានារ៉ាប់រង ១លើក ii/-ក្រុមហ៊ុនកាស៊ីណូ ២លើក និង iii/-ក្រុមហ៊ុនអចលនទ្រព្យ ២លើក និងបានរៀបចំកិច្ចប្រជុំផ្លាស់ប្តូរព័ត៌មានជាមួយតំណាងសមាគមធនាគារនៅកម្ពុជា ដើម្បីជំរុញការអនុវត្តច្បាប់និងបទប្បញ្ញត្តិ និងការចែករំលែកព័ត៌មាននិងបទពិសោធន៍ថ្មីៗ។

### ៣- ការអនុវត្តសកម្មភាពការងារក្នុងយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣

បន្ទាប់ពីដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីខែមីនា ឆ្នាំ២០១៩ នូវយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣ មក ស.ហ.ក បានរៀបចំកម្មវិធីប្រជុំតាមគ្រា ដើម្បីតាមដានវឌ្ឍនភាពការងារ តាមអាទិភាពខ្ពស់ ផុតកំណត់ចុងឆ្នាំ២០១៩ ដែលមានក្នុងយុទ្ធសាស្ត្រជាតិនេះ តាមការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន រៀងៗខ្លួន។

### ៤- កិច្ចសហប្រតិបត្តិការ

#### ក- កិច្ចសហប្រតិបត្តិការក្នុងស្រុក

ដើម្បីបង្កើនសមត្ថភាពពាក់ព័ន្ធនឹងការផ្លាស់ប្តូរព័ត៌មានលើការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងអភិវឌ្ឍផែនការសកម្មភាពដែលកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិ ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣ ស.ហ.ក បានចុះអនុស្សរណៈយោគយល់ស្តីពីការផ្លាស់ប្តូរព័ត៌មានជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងទេសចរណ៍ អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងបានផ្លាស់ប្តូរជំនាញវិភាគនិងបទពិសោធន៍ការងារស៊ើបអង្កេត ឱ្យមានប្រសិទ្ធភាពជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ស្របតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលផងដែរ។

## ខ- កិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ

ស.ហ.ក បានផ្លាស់ប្តូរព័ត៌មានជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុបរទេស និងចែករំលែកបទពិសោធន៍ពីវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើហានិភ័យជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុឡាវផងដែរ។ ទន្ទឹមនេះ ស.ហ.ក បានសហការជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (APG) និងក្រុមអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ EGMONT ក្នុងក្របខ័ណ្ឌពង្រឹងប្រព័ន្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ស.ហ.ក ក៏បានពង្រឹងការសហការជាមួយបណ្តាស្ថាប័នផ្សេងទៀត រួមមាន៖

- មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) លើការងារ រួមមាន៖ i/-ការធ្វើវិសោធនកម្មច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ii/-ការរៀបចំឧបករណ៍ត្រួតពិនិត្យផ្អែកលើហានិភ័យនិងនីតិវិធីត្រួតពិនិត្យដល់ទីកន្លែងរបស់ ស.ហ.ក និង iii/-ការពង្រឹងមុខងារវិភាគ
- ក្រុមការងារប្រឹក្សាយោបល់ព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ (FICG) លើការសិក្សានិងវាយតម្លៃលើការងារ រួមមាន៖ i/-ការវាយតម្លៃហានិភ័យសម្អាតប្រាក់ក្នុងតំបន់ ii/-ទ្រព្យសកម្មនិម្មិត (Virtual Assets) និង iii/-យន្តការផ្លាស់ប្តូរព័ត៌មានពហុភាគីតាមប្រព័ន្ធអនឡាញ
- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុអូស្ត្រាលី (AUSTRAC)៖ ការបណ្តុះបណ្តាលស្តីពីការវិភាគព័ត៌មានស៊ើបការណ៍ហិរញ្ញវត្ថុ
- ការិយាល័យអង្គការសហប្រជាជាតិស្តីពីគ្រឿងញៀននិងបទឧក្រិដ្ឋ (UNODC)៖ ការបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រស៊ើបអង្កេត និង
- ធនាគារពិភពលោករៀបចំ៖ i/-ឧបករណ៍ត្រួតពិនិត្យនិងឯកសារផ្សព្វផ្សាយដល់វិស័យកាស៊ីណូ និងអចលនទ្រព្យ និង ii/-ផ្តល់ជំនួយបច្ចេកទេសនិងបទពិសោធន៍អនុវត្តការត្រួតពិនិត្យផ្អែកលើហានិភ័យដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុប្រទេសឡាវ។

# VII- កិច្ចសហប្រតិបត្តិការអន្តរជាតិ

## ១- កិច្ចសហប្រតិបត្តិការពហុភាគី

ធនាគារជាតិនៃកម្ពុជាបន្តពង្រឹងនិងពង្រីកកិច្ចសហការប្រតិបត្តិការជាមួយស្ថាប័នអន្តរជាតិ ដូចជា៖ i/-មូលនិធិរូបិយវត្ថុអន្តរជាតិ បានបន្តតាមដាននិងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចនិងផ្តល់ជំនួយបច្ចេកទេស ii/-ធនាគារពិភពលោក បានបន្តផ្តល់ជំនួយបច្ចេកទេសក្នុងការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ឆ្នាំ២០១៨-២០២៣ iii/-ធនាគារអភិវឌ្ឍន៍អាស៊ី បានសហការរៀបចំវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុលើកទី២ ផ្តល់ជំនួយបច្ចេកទេសក្នុងការបង្កើតប្រព័ន្ធមូលដ្ឋានទិន្នន័យស្វ័យប្រវត្តិ និងបញ្ចប់ការអនុវត្តអនុកម្មវិធីទី២នៃកម្មវិធីអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន និងត្រៀមផ្តល់ជំនួយបច្ចេកទេសសម្រាប់ការអនុវត្តអនុកម្មវិធីទី៣ iv/-មជ្ឈមណ្ឌលស៊ាសិន បានសហការរៀបចំវគ្គបណ្តុះបណ្តាលពិសេសស្តីពីការអនុវត្តនិងការគ្រប់គ្រងហានិភ័យសន្ទនីយភាព និង v/-មូលនិធិអភិវឌ្ឍទុនរបស់អង្គការសហប្រជាជាតិ បានបញ្ចប់ការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានពង្រឹងកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័នអន្តរជាតិផ្សេងទៀតដូចជា សហព័ន្ធបរិយាបន្នហិរញ្ញវត្ថុ (AFI), សមាគមឥណទានជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក (APRACA), ក្រុមប្រទេសនិយាយភាសាបារាំង(Francophone), ក្រុមប្រឹក្សាពិគ្រោះយោបល់ស្ថិរភាពហិរញ្ញវត្ថុប្រចាំតំបន់អាស៊ី (FSB-RGC for Asia) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ជាដើម។

ចំពោះកិច្ចសហប្រតិបត្តិការក្រោមក្របខ័ណ្ឌអាស៊ាន ធនាគារជាតិនៃកម្ពុជាបានបន្តរួមចំណែក

និងសហការសម្រេចនូវវឌ្ឍនភាពសំខាន់ៗ ដូចជា៖ i/-សេរីភាវូបនីយកម្មគណនីមូលធន (CAL) ៖ គណៈកម្មាធិការ CAL បានបញ្ចប់ការរៀបចំផែនការសេរីភាវូបនីយកម្មគណនីមូលធននិងសេចក្ដីព្រាងស្ដីពីលក្ខខណ្ឌកំណត់, ii/-សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (FSL) ៖ គណៈកម្មាធិការ FSL បញ្ចប់ការពិភាក្សាបើកចំហសេវាហិរញ្ញវត្ថុកញ្ចប់ទី៩ iii/-ប្រព័ន្ធទូទាត់សងប្រាក់ (PSS) ៖ គណៈកម្មាធិការ PSS ទទួលបានការឯកភាពលើក្របខណ្ឌគោលនយោបាយសម្រាប់ភ្ជាប់ប្រព័ន្ធទូទាត់ឆ្លងដែន iv/-ការអភិវឌ្ឍទីផ្សារទុន (CMD) ៖ គណៈកម្មាធិការ CMD បន្តពង្រឹងតួនាទីទីផ្សារទុនអាស៊ានសំដៅគាំទ្រការធ្វើហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ និងលើកកម្ពស់កម្មវិធីហិរញ្ញប្បទានបៃតង v/-ក្របខ័ណ្ឌសមាហរណកម្មវិស័យធនាគារ (ABIF) ៖ គណៈកម្មាធិការ ABIF បានចែករំលែកបទពិសោធន៍និងកំណត់បញ្ហាប្រឈមលើដំណើរការចរចាកិច្ចព្រមព្រៀង ABIF និងបញ្ចប់សម្រង់បញ្ជីអំពីបទដ្ឋាននៃការគ្រប់គ្រង ស្រោចស្រង់ និងដោះស្រាយវិបត្តិ vi/-បរិយាបន្នហិរញ្ញវត្ថុ (FINC) ៖ គណៈកម្មាធិការ FINC បន្តរៀបចំយុទ្ធសាស្ត្របរិយាបន្នហិរញ្ញវត្ថុនិងផែនការអនុវត្ត ពង្រឹងការកសាងសមត្ថភាពបង្កើននវានុវត្តន៍តាមប្រព័ន្ធឌីជីថល និងបង្កើតយន្តការបង្កើនចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន និង vii/- ការកសាងសមត្ថភាព (SCCB) ៖ គណៈកម្មាធិការ SCCB បន្តរួមចំណែកក្នុងការកសាងសមត្ថភាពមន្ត្រីធនាគារកណ្ដាលរបស់ប្រទេស BCLMV ក្រោមសសរស្ដម្ភ៣[១៨]។ នៅក្នុងឆ្នាំ២០១៩នេះ កម្ពុជាទទួលបានវគ្គបណ្ដុះបណ្ដាលស្ដីពី ការត្រួតពិនិត្យធនាគារនិងស្ថិរភាពហិរញ្ញវត្ថុ ការគ្រប់គ្រងលំហូរមូលធន ការផ្លាស់ប្ដូរពីអភិក្រមវិជ្ជមានទៅជាអវិជ្ជមាន ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុ ជាដើម។

ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអាស៊ាន+៣ ការងារសំខាន់ដែលសម្រេចបាន រួមមាន៖ i/-ការអនុម័តលើការកែសម្រួលកិច្ចព្រមព្រៀង CMIM ii/-ការកែសម្រួលគោលការណ៍ប្រតិបត្តិនៃកិច្ចព្រមព្រៀង CMIM iii/-ការសាកល្បងលើកទី១០ ដោយមានការសាកល្បងដកសាច់ប្រាក់ជាក់ស្ដែង iv/-ការទទួលបានជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាព និងការតាមដានស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកម្ពុជា និង v/-ការបន្តជំរុញការបោះសញ្ញាប័ណ្ណជារូបិយវត្ថុក្នុងស្រុកជាដើម។

### ២- កិច្ចសហប្រតិបត្តិការទ្វេភាគី

ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំទ្វេភាគីប្រចាំឆ្នាំជាមួយធនាគារកណ្ដាលវៀតណាម ធនាគារកណ្ដាលឡាវ និងធនាគារកណ្ដាលថៃ ក្នុងគោលបំណងរឹតចំណងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងជាមិត្តភាព ក៏ដូចជាផ្លាស់ប្ដូរបទពិសោធន៍លើការងារជំនាញនានា។ ម្យ៉ាងទៀត ធនាគារជាតិនៃកម្ពុជាបានចុះអនុស្សរណៈយោគយល់ ៖ i/-ជាមួយធនាគារកណ្ដាលថៃ ស្ដីពី "កិច្ចសហប្រតិបត្តិការលើនវានុវត្តន៍នៃការទូទាត់និងហិរញ្ញវត្ថុ" និងបានចូលរួមក្នុងកម្មវិធីដាក់បង្ហាញពីការតភ្ជាប់ប្រព័ន្ធទូទាត់តាម QR Code ដែលអនុញ្ញាតឱ្យមានការទូទាត់រាយឆ្លងដែនរវាងបុគ្គលនិងពាណិជ្ជករក្នុងប្រទេសទាំងពីរ ប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងឆាប់រហ័ស និង ii/-ជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរី ស្ដីពី ការពង្រឹងកិច្ចសហប្រតិបត្តិការលើផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech)។ ទន្ទឹមនេះ ធនាគារកណ្ដាល

---

[១៨] សសរស្ដម្ភ៣៖ A (វគ្គបណ្ដុះបណ្ដាលមូលដ្ឋានដែលផ្ដល់លទ្ធភាពឱ្យមានអ្នកចូលរួមបានច្រើន) B (លើការពង្រឹងសមត្ថភាពក្រុមការងារជំនាញ ការចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមក និងការពិភាក្សាក្នុងតំបន់) និង C (ការធ្វើទស្សនកិច្ចសិក្សានៅបណ្ដាប្រទេសអាស៊ាន-៥)។

កូរ៉េបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយធនាគារជាតិនៃកម្ពុជាស្តីពីការស្រាវជ្រាវរួមគ្នាក្រោមកម្មវិធី "ភាពជាដៃគូផ្តល់ចំណេះដឹង" សម្រាប់ឆ្នាំ២០១៩ លើប្រធានបទ "ការអភិវឌ្ឍទីផ្សារអន្តរធនាគារនៅកម្ពុជា"។

## VIII- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សមាសភាព និងសកម្មភាពក្រុមប្រឹក្សាភិបាល

បច្ចុប្បន្ន ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិកា |
| - ឯកឧត្តម ជូ គឹមឡេង | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ីវ ចុង | តំណាងឱ្យមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម រស់ សីលវ៉ា | តំណាងឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - ឯកឧត្តម ឡាយ ម៉េងស៊ុន | តំណាងឱ្យមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក និង |
| - លោក មុំ ដារ៉េត | តំណាងឱ្យបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក។ |

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានជួបប្រជុំចំនួន ៦ លើក គឺកិច្ចប្រជុំក្រុមប្រឹក្សាភិបាល៖

i/- លើកទី១៣២ កាលពីថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩ ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជា សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៨។

ii/- លើកទី១៣៣ កាលពីថ្ងៃចន្ទ ៦រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩ ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេច របាយការណ៍ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០១៨ និងផែនការឆ្នាំ២០១៩។

iii/- លើកទី១៣៤កាលពីថ្ងៃ ពុធ ៣កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩ ដើម្បីពិភាក្សាលើ៖ ១/-ប្រកាសសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាអាណត្តិថ្មី, ២/-របាយការណ៍ស្តីពីសកម្មភាពការងារគ្រប់គ្រងទុនបម្រុងវិនិយោគឆ្នាំ២០១៨ និង ៣/-ប្រកាសស្តីពីរចនាសម្ព័ន្ធ និងមុខងារ-ភារកិច្ចរបស់នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការអន្តរជាតិ។

iv/- លើកទី១៣៥ កាលពីថ្ងៃព្រហស្បតិ៍ ២រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ឆ្នាំ២០១៩។

v/- លើកទី១៣៦ កាលពីថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីពិនិត្យនិងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្តីពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុ ប្រចាំត្រីមាសទី២ ឆ្នាំ២០១៩ និង

vi/- លើកទី១៣៧ កាលពីថ្ងៃព្រហស្បតិ៍ ៨រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវ

នឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ដើម្បីពិនិត្យនិងអនុម័តលើសេចក្ដីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៩ និង ទិសដៅការងារឆ្នាំ២០២០។

### ២- ការអភិវឌ្ឍធនធានមនុស្ស

ធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា មានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ដែល ឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃបរិមាណមន្ត្រីបុគ្គលិកប្រកបដោយគុណវុឌ្ឍិ រចនាសម្ព័ន្ធការងារ រឹងមាំ និងការងារប្រកបដោយប្រសិទ្ធភាព។ បច្ចុប្បន្ន ការគ្រប់គ្រងធនធានមនុស្ស ត្រូវបានអភិវឌ្ឍ ស្របនឹងតម្រូវការនៃសមាហរណកម្ម នៅក្នុងតំបន់និងពិភពលោក ព្រមទាំងគោលការណ៍នៃស្ថិរភាព និងប្រសិទ្ធភាពការងារ។

#### ក- ស្ថិតិមន្ត្រីបុគ្គលិក

ក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសប្រចាំឆ្នាំ២០១៩នេះ មានចំនួន ១.៦៦៧រូប (ស្រី ៨០០រូប) ក្នុងនោះទីស្នាក់ការកណ្ដាលមានចំនួន ១.២១០រូប (ស្រី ៥៦៧រូប) និង សាខារាជធានី-ខេត្ត មានចំនួន ៤៥៧រូប (ស្រី ២៣៣រូប)។ ក្នុងឆ្នាំនេះ ក្របខ័ណ្ឌមន្ត្រីនៅទីស្នាក់ការ កណ្ដាលបានកើនឡើងចំនួន ២០រូប (ចូលថ្មី ៥២រូប ផ្ទេរចូល ៣រូប ចូលនិវត្តន៍ ១០រូប លាឈប់ ១៣រូប ផ្ទេរចេញ ១រូប មរណភាព ១រូប) ខណៈនៅសាខា បានថយចុះចំនួន ១៦រូប (ចូលនិវត្តន៍ ១១រូប ផ្ទេរចេញ ៣រូប លាឈប់ ១រូប មរណៈភាព ១រូប)។

**ស្ថិតិមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាប្រចាំឆ្នាំ២០១៩**

| | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | បម្រែបម្រួល |
|---|---|---|---|---|---|---|
| **ទីស្នាក់ការកណ្ដាល** | ប្រុស | ៥៨២ | ៦២២ | ៦៤០ | ៦៤៣ | ៣ |
| | ស្រី | ៤៦៩ | ៥៥៣ | ៥៥០ | ៥៦៧ | ១៧ |
| | សរុប | ១០៥១ | ១១៧៥ | ១១៩០ | ១២១០ | ២០ |
| **សាខា** | ប្រុស | ២២៨ | ២៣៥ | ២៣២ | ២២៤ | -៨ |
| | ស្រី | ២៣៥ | ២៤៤ | ២៤១ | ២៣៣ | -៨ |
| | សរុប | ៤៦៣ | ៤៧៩ | ៤៧៣ | ៤៥៧ | -១៦ |
| **សរុបទូទាំងប្រទេស** | ប្រុស | ៨១០ | ៨៥៧ | ៨៧២ | ៨៦៧ | -៥ |
| | ស្រី | ៧០៤ | ៧៩៧ | ៧៩១ | ៨០០ | ៩ |
| | សរុប | **១៥១៤** | **១៦៥៤** | **១៦៦៣** | **១៦៦៧** | ៤ |

#### ខ- ការបណ្ដុះបណ្ដាល

**- ការបណ្ដុះបណ្ដាលក្នុងប្រទេស**

ធនាគារជាតិនៃកម្ពុជាបានរៀបចំបើកវគ្គសិក្ខាសាលាចំនួន ១៦លើក (សិក្ខាកាម ៤០០រូប) វគ្គសិក្សាចំនួន៤លើក (សិក្ខាកាម ២០០រូប) កិច្ចប្រជុំចំនួន ១២លើក (មន្ត្រីបុគ្គលិក ១.២០០រូប) និង បានរៀបចំកម្មវិធីចុះកម្មសិក្សានៅធនាគារជាតិនៃកម្ពុជាជូននិស្សិតមកពីបណ្ដាគ្រឹះស្ថានឧត្តមសិក្សា ចំនួន ១៨លើក ដោយមាននិស្សិតចូលរួម ២២៥រូប។

ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានបន្តបណ្ដុះបណ្ដាលមន្ត្រីបុគ្គលិកតាមប្រព័ន្ធ Online

ចំនួន៤វគ្គ រួមមាន៖ i/-កម្មវិធីបណ្តុះបណ្តាល FSI Connect ជំនាញត្រួតពិនិត្យធនាគារ មាន៣ជំនាន់ (សិក្ខាកាមសរុប ២៥៨រូប - អាហារូបករណ៍ ២៥រូប) ក្នុងនោះមន្ត្រីបុគ្គលិកប្រឡងបញ្ចប់កម្រិតបឋម មាន ១២៣រូប កម្រិតមធ្យម ២០រូប និងកម្រិតខ្ពស់ ១រូប ii/-កម្មវិធីបណ្តុះបណ្តាល BIS-IMF ស្តីពីការត្រួតពិនិត្យនិងបទប្បញ្ញត្តិធនាគារ មាន ២លើក (សិក្ខាកាមសរុប ១០រូប ក្នុងនោះមាន ៥រូប បានប្រឡងបញ្ចប់ការសិក្សា) iii/-កម្មវិធីបណ្តុះបណ្តាល IMF ស្តីពីកម្មវិធីនិងគោលនយោបាយហិរញ្ញវត្ថុ (FPP) មាន ២ជំនាន់ (សិក្ខាកាមសរុប ៦៤រូប ក្នុងនោះមាន ៤រូប បានប្រឡងបញ្ចប់) និង iv/-វគ្គសិក្សាអំពីបច្ចេកវិទ្យាហិរញ្ញវត្ថុ និងនវានុវត្តន៍បទប្បញ្ញត្តិ (Fintech & Regulatory Innovation) របស់សាកលវិទ្យាល័យ Cambridge មានសិក្ខាកាម ២រូប កំពុងសិក្សា។

បន្ថែមលើនេះ មណ្ឌលសិក្សាបច្ចេកទេសធនាគារបានបន្តបណ្តុះបណ្តាលមន្ត្រីបុគ្គលិក និងនិស្សិត ថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ។ មណ្ឌលសិក្សាមានសាស្ត្រាចារ្យ ៥៦រូប (ស្រី ១០រូប) ក្នុងនោះសាស្ត្រាចារ្យក្នុងប្រព័ន្ធធនាគារជាតិនៃកម្ពុជាមាន ៤២រូប (ស្រី ៥រូប)។ បច្ចុប្បន្ន និស្សិតដែលបាននិងកំពុងសិក្សាមាន ៤០៦រូប (ស្រី ៣០៤រូប)រួមមាននិស្សិតជំនាន់ទី២៧ (១២៧រូបបានបញ្ចប់ការសិក្សា), ជំនាន់ទី២៨ (១៣៤រូប) និងជំនាន់ទី២៩ (១៤៥រូប)។

**- ការបណ្តុះបណ្តាលក្រៅប្រទេស**

ធនាគារជាតិនៃកម្ពុជាបានបន្តបង្កើនសមត្ថភាពនិងអភិវឌ្ឍធនធានមនុស្សនៅក្រៅប្រទេស តាមរយៈការចាត់បញ្ជូនមន្ត្រីបុគ្គលិកឱ្យចូលរួមវគ្គសិក្សារយៈពេលខ្លីចំនួន ១៣០លើក (មន្ត្រីបុគ្គលិក ២៥៦រូប) វគ្គសិក្សារយៈពេលវែងថ្នាក់អនុបណ្ឌិតចំនួន ១៤លើក (មន្ត្រីបុគ្គលិក ២២រូប) ប្រជុំនិងទស្សនកិច្ចសិក្សាចំនួន ១៧៩លើក (មន្ត្រីបុគ្គលិក ៤៧១រូប)។

## ៣- សវនកម្មផ្ទៃក្នុង អធិការកិច្ច និងការគ្រប់គ្រងហានិភ័យ

នៅឆ្នាំនេះ ការធ្វើសវនកម្មលើប្រតិបត្តិការធនាគារស្នូលត្រូវបានអនុវត្តចំពោះនាយកដ្ឋាន ២ (នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ និងនាយកដ្ឋានបោះផ្សាយនិងឃ្លាំងបេឡា) និងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តចំនួន៩ (ខេត្តព្រៃវែង បន្ទាយមានជ័យ កំពង់ឆ្នាំង កោះកុង ស្ទឹងត្រែង ពោធិ៍សាត់ រតនគិរី បាត់ដំបង និងព្រះសីហនុ) ។ ទន្ទឹមនេះ ការតាមដានការអនុវត្តតាមអនុសាសន៍ សម្រេចបាន ៣ នាយកដ្ឋាននៅស្នាក់ការកណ្តាល និង ៧ សាខា។ ចំណែកឯ ការងារអធិការកិច្ចដែលផ្តោតលើការគ្រប់គ្រងនិងរក្សាសុវត្ថិភាពសាច់ប្រាក់ក្នុងឃ្លាំង និងការប្រតិបត្តិតាមការណែនាំ បានអនុវត្តនៅសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តទាំង១៩។

ការគ្រប់គ្រងហានិភ័យ ត្រូវបានលើកកម្ពស់ តាមរយៈការរៀបចំសិក្ខាសាលាចែករំលែកការយល់ដឹងអំពីហានិភ័យ សម្រាប់មន្ត្រីបុគ្គលិកនៅស្នាក់ការកណ្តាលនិងសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តចំនួន ៨លើក និងកិច្ចប្រជុំគណៈកម្មការគ្រប់គ្រងហានិភ័យប្រព័ន្ធធនាគារស្នូល ១១លើក ដើម្បីពិនិត្យពិភាក្សាលើកម្រងឯកសារណែនាំស្តីពីប្រតិបត្តិការសម្រាប់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត និងលទ្ធផលនៃការអនុវត្តការងារប្រព័ន្ធធនាគារស្នូលជំនាន់ ១២.៣ (V 12.3)។

### ៤- ការគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាបាននិងកំពុងពង្រឹងនិងពង្រីកសមត្ថភាពប្រតិបត្តិការនៅតាមសាខារាជធានី-ខេត្តទាំង ១៩ សំដៅគ្រប់គ្រងការធ្វើចរាចរសាច់ប្រាក់នៅក្នុងប្រព័ន្ធធនាគារឱ្យបានកាន់តែទូលំទូលាយតាមរយៈការផ្តល់សេវា (គ្រប់គ្រងគណនី ទទួលនិងបើកសាច់ប្រាក់ និងផ្ទេរប្រាក់) ជូនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រសួង-មន្ទីរ និងអង្គភាពរបស់រាជរដ្ឋាភិបាល ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។ បន្ថែមលើនេះ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត បានផ្តល់សេវាប្តូរក្រដាសប្រាក់រៀលចាស់ សឹករេចរឹល ទក់រហែកដល់សាធារណជន ដើម្បីជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ។

## សេចក្តីសន្និដ្ឋាន

នៅឆ្នាំ២០១៩នេះ កំណើនសេដ្ឋកិច្ចកម្ពុជាបន្តមានកំណើនរឹងមាំ ដែលគាំទ្រដាចម្បងដោយវិស័យកម្មន្តសាល សំណង់ និងទេសចរណ៍ ទោះបីជាកំណើនសេដ្ឋកិច្ចពិភពលោកបានថមថយល្បឿនយ៉ាងណាក្តី។ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចបន្តមានស្ថិរភាពល្អប្រសើរ ដែលឆ្លុះបញ្ចាំងតាមរយៈកម្រិតទាបអត្រាអតិផរណា និងស្ថិរភាពអត្រាប្តូរប្រាក់។ ទុនបម្រុងអន្តរជាតិត្រូវបានគរពូនឱ្យស្ថិតក្នុងកម្រិតខ្ពស់បន្ថែមទៀត ដែលរួមចំណែកបង្កើនជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគិន។

វិស័យធនាគារបន្តមានស្ថិរភាពល្អប្រសើរ និងបានជំរុញបរិយាបន្នហិរញ្ញវត្ថុឱ្យកើនឡើងជាលំដាប់ ព្រមទាំងបានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។ ជាមួយគ្នានេះ ប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានធ្វើទំនើបកម្មជាលំដាប់ទៅលើការទូទាត់តម្លៃរាយនិងតម្លៃធំ ស្របតាមការកើនឡើងការទូទាត់អេឡិចត្រូនិក។ ដើម្បីបន្តរក្សាស្ថិរភាពហិរញ្ញវត្ថុ ការត្រួតពិនិត្យនិងការវិភាគលើហានិភ័យរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវបានអនុវត្តជាប្រចាំ ហើយវិធានការម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្ននានាដែលមានលក្ខណៈបុរេសកម្ម ត្រូវបានដាក់ចេញជាបន្តបន្ទាប់ សំដៅពង្រឹងភាពធន់និងកាត់បន្ថយហានិភ័យជាប្រព័ន្ធ។ បន្ថែមលើនេះ ការងារបរិយាបន្នហិរញ្ញវត្ថុ និងការអប់រំផ្នែកហិរញ្ញវត្ថុ ត្រូវបានបន្តលើកកម្ពស់យ៉ាងសកម្ម តាមរយៈយុទ្ធនាការនិងការផ្សព្វផ្សាយផ្សេងៗ ក្រោមកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរតាមមូលដ្ឋាន វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា។

ការពង្រឹងអភិបាលកិច្ចនិងធនធានមនុស្ស ត្រូវបានបន្តអភិវឌ្ឍយ៉ាងយកចិត្តទុកដាក់ សំដៅបង្កើនប្រសិទ្ធភាពនិងគណនេយ្យភាពសេវាធនាគារកណ្តាល ស្របនឹងគោលការណ៍ស្ថិរភាព និងប្រសិទ្ធភាពការងារ ឆ្លើយតបនឹងការរីកចម្រើនសេដ្ឋកិច្ច និងនិម្មាបនកម្មហិរញ្ញវត្ថុអន្តរជាតិ។ ស្ថិតក្នុងបរិការណ៍សមាហរណកម្មសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកាន់តែស៊ីជម្រៅ កិច្ចសហប្រតិបត្តិការអន្តរជាតិក៏ត្រូវបានលើកកម្ពស់ជាប្រចាំ ដើម្បីផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មាន និងទទួលបានជំនួយបច្ចេកទេសនានា ដើម្បីរួមចំណែកពង្រឹងសេវាធនាគារកណ្តាល និងសមត្ថភាពមន្ត្រីបុគ្គលិក។

